រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# របាយការណ៍

# ស្តីពី

# វឌ្ឍនភាពនៃកិច្ចដំណើរការអភិវឌ្ឍតាមបែប
# ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
# ឆ្នាំ២០១១

ខែមករា ឆ្នាំ២០១២

# មាតិកា


**I. សេចក្តីផ្តើម** ---------------------------------------------------------------------------- 01

**II. សមិទ្ធផល** ---------------------------------------------------------------------------- 03

**ក-)ការអភិវឌ្ឍន៍គោលនយោបាយ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ** -------- 03

១-) ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ------------------ 03

២-) ប្រព័ន្ធរៀបចំផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ------------------------------ 04

៣-)ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ---------------------------------------- 05

៤-) ប្រព័ន្ធគណនេយ្យភាពរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ---------------------- 06

៥-) ការរៀបចំប្រគល់ និងផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ---------------------------- 07

៦-) ការរៀបចំប្រព័ន្ធអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ---------------------------- 08

៧-) ការរៀបចំយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ---------------------------------------------------- 08

៨-) ការកែសម្រួលរចនាសម្ព័ន្ធលេខាធិការដ្ឋានគ.ជ.អ.ប ------------------------------------ 09

**ខ-) អំពីការរៀបចំ និងអនុវត្តកម្មវិធី** ---------------------------------------------------------- 10

១-) ផអ៣ និងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១១នៃផអ៣ ------------------------ 10

២-) ការអនុវត្តអនុកម្មវិធីទី១: ការរៀបចំគោលនយោបាយ និងការសម្របសម្រួលកម្មវិធី ------ 14

៣-) ការអនុវត្តអនុកម្មវិធីទី២: ការរៀបចំ និងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងបុគ្គលិករបស់ រដ្ឋបាលថ្នាក់ក្រោមជាតិ ------------------------------------------ 16

៤-) ការអនុវត្តអនុកម្មវិធីទី៣: ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ -------- 18

៥-) ការអនុវត្តអនុកម្មវិធីទី៤: ធនធានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ----------------------- 19

៦-) ការអនុវត្តអនុកម្មវិធីទី៥: ប្រព័ន្ធកសាងផែនការ និងកម្មវិធីវិនិយោគរដ្ឋបាលថ្នាក់ ក្រោមជាតិ -------------------------------------------------------------------- 21

៧-) ការអនុវត្តអនុកម្មវិធីទី៦: ការអភិវឌ្ឍសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ ក្រោមជាតិ -------------------------------------------------------------------- 23

៨-) ការគាំទ្រដល់ឃុំ សង្កាត់ ------------------------------------------------------------ 24

**គ-) អំពីការកៀរគរធនធាន និងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍** ---------------------------- 24

**III. បញ្ហាប្រឈមជាគន្លឹះ និងដំណោះស្រាយ** --------------------------------------------- 29

ក-) ស្ថាប័ន និងប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ------------------------------ 29

ខ-) ប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ---------------------------------- 29
គ-) ការរៀបចំលិខិតបទដ្ឋានសម្រាប់ការគ្រប់គ្រងធនធានហិរញ្ញវត្ថុក្រុង ស្រុក ------------------- 30
ឃ-) ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ----------------------------------------------- 31
ង-) ការពង្រឹងគណនេយ្យភាពរដ្ឋបាលថ្នាក់ក្រោមជាតិ --------------------------------------------- 32
ច-) យន្តការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ------------------------------------------------------- 32
ឆ-) ការបញ្ជ្រាបយេនឌ័រ ------------------------------------------------------------------------------------- 33
ជ-) ការផ្សព្វផ្សាយព័ត៌មាន ----------------------------------------------------------------------------------- 34
ឈ-) ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ----------------------------------------------------------- 34
ញ-) ប្រព័ន្ធចំណាយប្រតិបត្តិការអាទិភាព ------------------------------------------------------------- 35
**IV.ផែនការឆ្នាំ២០១២** ------------------------------------------------------------------------------------------- 36
**V.សេចក្តីសន្និដ្ឋាន** ---------------------------------------------------------------------------------------------- 39

# I. សេចក្តីផ្តើម

ឆ្នាំ២០១១ គឺជាឆ្នាំនៃការចាប់ផ្តើមអនុវត្តនូវកិច្ចដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរបត់ថ្មីមួយ ដែលបានកំណត់នៅក្នុងកម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា នា**ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០** ហើយត្រូវបានប្រកាសផ្សព្វផ្សាយឱ្យអនុវត្តជាផ្លូវការនៅក្នុងសិក្ខាសាលាជាតិ នា**ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១០** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ របត់ថ្មីនៃកំណែទម្រង់នេះ គឺការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលមានលក្ខណៈស៊ីជម្រៅនៅថ្នាក់ក្រោមជាតិ ជាពិសេសដោយផ្តោតទៅលើការរៀបចំបង្កើត និងការអភិវឌ្ឍន៍នូវរដ្ឋបាលឯកភាពប្រកបដោយប្រសិទ្ធភាពនៅថ្នាក់ក្រុង ស្រុក ការបន្តនិរន្តរភាពនៃការគាំទ្រដល់ថ្នាក់ឃុំ សង្កាត់ ព្រមទាំងការពង្រឹងតួនាទីថ្នាក់រាជធានី ខេត្ត ក្នុងការសម្របសម្រួល ការគាំទ្រ និងការតាមដានត្រួតពិនិត្យ ដោយផ្អែកលើមូលដ្ឋានដ៏រឹងមាំនៃបទពិសោធន៍ក្នុងដំណើរការកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់កន្លងមក។

បទពិសោធន៍នៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ក្នុងអំឡុងពេលប្រមាណជិតមួយទសវត្សរ៍កន្លងមក បានបង្ហាញឱ្យឃើញនូវលទ្ធផលជាវិជ្ជមានដ៏រឹងមាំ និងគួរឱ្យកត់សម្គាល់ក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ការពង្រឹងអភិបាលកិច្ចល្អ ការកែលំអគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ តាមរយៈការសិក្សា និងវិភាគលើទិន្នន័យ ដែលប្រមូលបានពីការធ្វើអង្កេតរបស់ គ.ជ.អ.ប និងអង្គការមិនមែនរដ្ឋាភិបាលបានបង្ហាញឱ្យឃើញពីការកើនឡើងនៃការចូលរួម និងការប្រាស្រ័យទាក់ទងរបស់ប្រជាពលរដ្ឋជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងបានឆ្លុះបញ្ចាំងឱ្យឃើញអំពីការកាត់បន្ថយនូវគម្លាតយេនឌ័រ ដោយបានបង្កើននូវសមភាពរវាងបុរស និងស្ត្រីក្នុងការចូលរួមក្នុងដំណើរការអភិបាលកិច្ចនៅមូលដ្ឋាន។

ការសិក្សារបស់មន្ត្រីជំនាញនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដោយសហការជាមួយអ្នកជំនាញវិទ្យាសាស្ត្រនយោបាយអន្តរជាតិ[1] បានបង្ហាញឱ្យឃើញនូវភស្តុតាងនៃការចូលរួមចំណែករបស់មូលនិធិអភិវឌ្ឍន៍តាមបែបវិមជ្ឈការ និងវិសហមជ្ឈការទៅលើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ក្នុងអត្រាវិជ្ជមានមួយដែលអាចបញ្ជាក់បានថា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានចូលរួមចំណែកប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ការសិក្សាទាំងនេះក៏បានឆ្លុះបញ្ចាំងផងដែរនូវសារៈសំខាន់នៃការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធជនបទនៃមូលនិធិឃុំ សង្កាត់ ក្នុងការជំរុញកំណើននៃសន្ទស្សន៍សុខមាលភាពរបស់ប្រជាពលរដ្ឋ ហើយជាពិសេស កំណើននៃសន្ទស្សន៍សុខមាលភាពនេះមានផលប៉ះពាល់ទៅលើគ្រួសារក្រីក្រ និងមធ្យមច្រើនជាង

---

[1] ការសិក្សាស្តីពីផលប៉ះពាល់នៃវិមជ្ឈការ និងវិសហមជ្ឈការទៅលើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា (វេទិកាសិក្សាស្រាវជ្រាវសម្រាប់កិច្ចអភិវឌ្ឍន៍ ,សិក្ខាសាលាប្រចាំឆ្នាំលើកទី៣ស្តីពី "គោលនយោបាយឆ្លើយបតទៅនឹងការស្តារឡើងវិញ និងការអភិវឌ្ឍន៍កម្ពុជា"នាខែកញ្ញា ឆ្នាំ២០១០)។ លទ្ធផលនៃការសិក្សានេះកំពុងត្រូវបានពិនិត្យដើម្បីបញ្ជាក់ឡើងវិញដោយលេខាធិការដ្ឋាន គ.ជ.អ.ប។

គ្រួសារដែលមានជីវភាពធូរធារ[2] ។ នេះបង្ហាញឱ្យឃើញថា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមិនត្រឹមតែបានចូលរួមចំណែកលើកកម្ពស់ជីវភាពរស់នៅ កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋប៉ុណ្ណោះនោះទេ គឺថែមទាំងបានចូលរួមចំណែកដល់ការកាត់បន្ថយគម្លាតរវាងក្រុមគ្រួសារដែលមានជីវភាពក្រីក្របំផុត និងក្រុមគ្រួសារដែលមានជីវភាពធូរធារបំផុត។ ក្រៅពីនេះ តាមរយៈលទ្ធផលនៃការអង្កេតជាបឋមអំពីរដ្ឋបាលថ្នាក់ក្រោមជាតិ[3] ដែលធ្វើឡើងដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីការអភិវឌ្ឍកម្ពុជា (CDRI) បានបង្ហាញឱ្យឃើញថា "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានរួមចំណែកពង្រឹងប្រជាធិបតេយ្យនៅមូលដ្ឋាន បានធ្វើឱ្យមានភាពប្រសើរឡើងនូវជីវភាពរបស់ប្រជាជន ពង្រឹងភាពជាអ្នកដឹកនាំនៅមូលដ្ឋានទាំងបុរស ទាំងស្ត្រី និងក៏បានធ្វើឱ្យមានការកែលំអនូវការផ្តល់សេវាសាធារណៈនៅមូលដ្ឋានផងដែរ" ។

ដើម្បីធានាបាននូវការតភ្ជាប់នៃកិច្ចដំណើរការកំណែទម្រង់ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដ៏មានសារៈសំខាន់ពីដំណាក់កាលទី១មកដំណាក់កាលបន្ទាប់ នៅក្នុងឆ្នាំ២០១១នេះ គ.ជ.អ.ប ព្រមទាំងអនុគណៈកម្មាធិការ និងលេខាធិការដ្ឋានរបស់ខ្លួនបានខិតខំប្រឹងប្រែងសម្របសម្រួល និងសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងជាមួយដៃគូអភិវឌ្ឍន៍នានាក្នុងការចាប់ផ្តើមអនុវត្តនូវផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង(២០១១-២០១៣) ដែលហៅកាត់ថា**ផអ៣** នៃកម្មវិធីជាតិ និងការរៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១១ដែលជាឆ្នាំទី១នៃផអ៣ ដើម្បីធ្វើឱ្យបានសម្រេចនូវសមិទ្ធផលសំខាន់ៗគួរជាទីមោទនៈ ដូចមានរៀបរាប់នៅក្នុងរបាយការណ៍នេះ។

ជាទូទៅរបាយការណ៍នេះរៀបរាប់សង្ខេបអំពីសមិទ្ធផលសំខាន់ធំៗចំនួន៣ ដែលសម្រេចបាននៅក្នុងឆ្នាំ២០១១ ដែលក្នុងនោះរួមមានៈ ១.)សមិទ្ធផលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍គោលនយោបាយ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ២.)ការរៀបចំ និងអនុវត្តកម្មវិធី និង៣.)ការកៀរគរធនធាន និងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងការគាំទ្រកិច្ចដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់នេះ។

ក្រៅពីការរៀបរាប់អំពីសមិទ្ធផលសំខាន់ៗនៃកិច្ចខិតខំប្រឹងប្រែងរបស់ គ.ជ.អ.ប ក្នុងការដឹកនាំ និងសម្របសម្រួលកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ របាយការណ៍នេះ ក៏បានគូសបញ្ជាក់ផងដែរអំពីបញ្ហាប្រឈមជាគន្លឹះ ទាំងផ្នែកគោលនយោបាយ និងផ្នែកប្រតិបត្តិការកម្មវិធីដែលបានជួបប្រទះក្នុងអំឡុងពេលនៃការអនុវត្ត ព្រមទាំងបានលើកឡើងនូវដំណោះស្រាយនានាសម្រាប់បន្តដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ។ ក្នុងរបាយការណ៍នេះ ក៏បានលើកឡើងផងដែរនូវសកម្មភាពជាអាទិភាពសំខាន់ៗដែល គ.ជ.អ.ប ត្រូវផ្តោតការយកចិត្តទុកដាក់អនុវត្តនៅក្នុងឆ្នាំ២០១២។ នៅចុងបញ្ចប់នៃរបាយការណ៍បានផ្តល់សេចក្តីសន្និដ្ឋាន និងវាយតម្លៃជារួមលើលទ្ធផលជាវិជ្ជមាននៃកិច្ចដំណើរការនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានឆ្លងផុតដោយជោគជ័យនូវដំណាក់កាលអន្តរកាលនៃឆ្នាំ២០១១នេះ។

---

[2] ការសិក្សាស្តីពីផលប៉ះពាល់នៃមូលនិធិឃុំ សង្កាត់ (វេទិកាសិក្សាស្រាវជ្រាវសម្រាប់កិច្ចអភិវឌ្ឍន៍ ,សិក្ខាសាលាប្រចាំឆ្នាំលើកទី៣ស្តីពី "គោលនយោបាយឆ្លើយបតទៅនឹងការស្តារឡើងវិញ និងការអភិវឌ្ឍន៍កម្ពុជា"នាខែកញ្ញា ឆ្នាំ២០១១)។

[3] ការអង្កេតបឋមអំពីរដ្ឋបាលថ្នាក់ក្រោមជាតិៈឆ្ពោះទៅកាន់ការយល់ដឹងកាន់តែប្រសើរអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅ កម្ពុជាបោះពុម្ពផ្សាយដោយ CDRI ខែធ្នូ ឆ្នាំ២០១១។

# II.សមិទ្ធផល

ក្រោមការខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់អនុវត្តតាមវិធីសាស្ត្រជាយុទ្ធសាស្ត្រនានា ដែលបានកំណត់នៅក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សមិទ្ធផលសំខាន់ៗមួយចំនួនត្រូវបានសម្រេចនៅក្នុងឆ្នាំ២០១១នេះ។ សមិទ្ធផលទាំងនោះ ពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍គោលនយោបាយ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការរៀបចំ និងអនុវត្តកម្មវិធី និងការកៀរគរធនធាន និងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍។

## ក-) ការអភិវឌ្ឍន៍គោលនយោបាយ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

ការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ការរៀបចំឡើងវិញ និងការពង្រឹងនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិ តាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ គឺជាលទ្ធផលរំពឹងទុកយ៉ាងសំខាន់ដែលបានកំណត់នៅក្នុងដំណាក់កាលនៃបណ្តាឆ្នាំដំបូងនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ ផអ៣នៃកម្មវិធីជាតិបានផ្តោតជាសំខាន់ទៅលើការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក។ ដោយឡែកនៅក្នុងឆ្នាំ២០១១ ដែលជាឆ្នាំអន្តរកាលនៃការតភ្ជាប់កិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដំណាក់ទី១ ដើម្បីឈានចូលមកការចាប់ផ្តើមអនុវត្តផអ៣នៃកម្មវិធីជាតិ សមិទ្ធផលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍គោលនយោបាយ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិដែលសម្រេចបានរួមមានដូចខាងក្រោម៖

### ១-) ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

លិខិតបទដ្ឋានគតិយុត្តសំខាន់ៗសម្រាប់ការរៀបចំកែសម្រួលរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រោមក្របខ័ណ្ឌនៃច្បាប់រៀបចំអង្គការ ត្រូវបានរៀបចំ និងដាក់ចេញរួចរាល់នៅក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១០។ ជាមួយគ្នានេះដែរ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក៏ត្រូវបានកែសម្រួល ហើយមន្ត្រីរាប់ពាន់នាក់ក៏ត្រូវបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធដែលបានកែសម្រួលទាំងនោះផងដែរ។ កិច្ចការសំខាន់ផ្សេងទៀតនៅក្នុងឆ្នាំ២០១១ គឺការផ្តោតទៅលើការរៀបចំបង្កើតគណៈកម្មាធិការពិគ្រោះយោបល់នានារបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងការសិក្សាដើម្បីរៀបចំសេចក្តីព្រាងគោលនយោបាយសម្រាប់គ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្របខ័ណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ នៅមុនពេលដែលមានលក្ខន្តិកៈដោយឡែកសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

នៅដើមឆ្នាំ២០១១ ក្រសួងមហាផ្ទៃបានរៀបចំ និងដាក់ចេញនូវសេចក្តីណែនាំស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសេចក្តីណែនាំស្តីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីឱ្យក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ធ្វើជាមូលដ្ឋានសម្រាប់ការបង្កើតគណៈកម្មាធិការនានារបស់ខ្លួនតាមការតម្រូវរបស់ច្បាប់រៀបចំអង្គការ។ មកដល់បច្ចុប្បន្ននេះ គណៈកម្មាធិការពិគ្រោះយោបល់ទាំងពីរប្រភេទត្រូវបានរៀបចំបង្កើតរួចរាល់នៅគ្រប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងអស់។ លើសពីនេះ តាមរយៈកិច្ចដំណើរការពិគ្រោះយោបល់ និងកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃក៏បានតាក់តែងសៀវភៅណែនាំស្តីពីតួនាទីភារកិច្ច និងរបៀបរបបការងាររបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីផ្តល់ការយល់ដឹងជាមូលដ្ឋាន និងជួយសម្រួលដល់ការអនុវត្តមុខងាររបស់ គ.ក.ស.ក។ សៀវភៅណែនាំនេះ ត្រូវបានឯកភាព និងដាក់ឱ្យប្រើប្រាស់នាខែតុលា ឆ្នាំ២០១១។

ពាក់ព័ន្ធទៅនឹងការរៀបចំគោលនយោបាយ និងក្របខណ្ឌគតិយុត្តសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ នៅមុនពេលដែលមានលក្ខន្តិកៈដោយឡែកសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈបានតាក់តែងនូវសេចក្តីព្រាងខ្លឹមសារគោលស្តីពីគោលនយោបាយគោលការណ៍រួម និងសេចក្តីព្រាងក្របខ័ណ្ឌគតិយុត្តអន្តរកាលសម្រាប់ការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដែលផ្តោតទៅលើនីតិវិធីសម្រាប់ជ្រើសរើសបុគ្គលិក ការដាក់ឱ្យធ្វើកម្មសិក្សា ការតាំងស៊ប់ ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ និងការតែងតាំងក្នុងមុខតំណែងនៃបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

**២-) ប្រព័ន្ធរៀបចំផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ៖**

ផ្អែកលើប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានអនុម័តនៅចុងឆ្នាំ២០១០ នៅដើមឆ្នាំ២០១១នេះ ក្រុមការងារដែលមានសមាសភាពពីលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ និងក្រសួងផែនការបានរៀបចំកែសម្រួលបញ្ចប់នូវសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ព្រមទាំងបានរៀបចំធ្វើជាឯកសារសម្រាប់បណ្តុះបណ្តាល និងផ្សព្វផ្សាយជូនដល់ក្រុមប្រឹក្សា មន្ត្រី និងអ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីផ្តល់ចំណេះជាមូលដ្ឋានផ្នែកបច្ចេកទេសសម្រាប់ការសម្របសម្រួល និងរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន។

សេចក្តីណែនាំស្តីពីការបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក៏ត្រូវបានរៀបចំដាក់ចេញនៅដើមឆ្នាំ២០១១ផងដែរ ដើម្បីផ្តល់ការណែនាំដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការរៀបចំបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ

និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរបស់ខ្លួន។ លើសពីនេះ ដើម្បីពង្រឹងកិច្ចដំណើរការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងផែនការក៏បានរៀបចំឯកសារណែនាំបច្ចេកទេសសំខាន់ៗនានាស្តីពីការវិភាគ និងការប្រើប្រាស់ទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ក្រុង ខណ្ឌ សម្រាប់ធ្វើការបណ្តុះបណ្តាលដល់មន្ត្រីពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ។ ផ្អែកតាមកិច្ចដំណើរការនេះ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗបានសម្រេចនូវការរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលជាលើកទី១របស់ខ្លួន។

**៣-) ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ៖**

ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុម័ត និងប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រម នស/រកម/០៦១១/០១១ នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១កន្លងទៅនេះ។ ផ្អែកលើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនេះ ក្រុមការងារបច្ចេកទេសលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានសហការគ្នាក្នុងការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក ដែលសេចក្តីព្រាងអនុក្រឹត្យនេះ នឹងត្រូវដាក់ជូន គ.ជ.អ.ប ពិនិត្យពិភាក្សា និងផ្តល់គោលការណ៍ណែនាំផ្អែកគោលនយោបាយលើចំណុចគន្លឹះមួយចំនួន មុននឹងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចនៅដើមឆ្នាំ២០១២។

ជាមួយគ្នានេះដែរ ក្រុមការងារក៏បាន និងកំពុងរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តចាំបាច់នានាសម្រាប់អនុវត្តប្រព័ន្ធទាំងនេះ ដែលរួមមាន៖ ១-) សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ២-)សេចក្តីព្រាងប្រកាសស្តីពីទម្រង់ និងមាតិកាថវិកាក្រុង ស្រុក ៣-) សេចក្តីព្រាងប្រកាសស្តីពីមាតិកាគណនីនៃគណនេយ្យថវិកាក្រុង ស្រុក ៤-) សេចក្តីណែនាំស្តីពីការរៀបចំ ការអនុម័ត និងការអនុវត្តថវិកាក្រុង ស្រុក និង៥-) សេចក្តីណែនាំស្តីពីការគ្រប់គ្រងសាច់ប្រាក់ និងប្រព័ន្ធទូទាត់ថវិកាក្រុង ស្រុក។ សេចក្តីព្រាងលិខិតបទដ្ឋានទាំងនេះក៏នឹងត្រូវដាក់ជូន គ.ជ.អ.ប ពិនិត្យពិភាក្សា និងសម្រេចជាបន្តបន្ទាប់ ដើម្បីធានាដល់ការចាប់ផ្តើមដាក់ឱ្យអនុវត្តនូវមូលនិធិក្រុង ស្រុកក្នុងឆ្នាំ២០១២។

ក្រៅពីការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនឹងមូលនិធិក្រុង ស្រុក លេខាធិការដ្ឋាន គ.ជ.អ.ប ដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត និងដោយមានការគាំទ្របច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី ក៏បានចាប់ផ្តើមសិក្សាអំពីប្រភពចំណូលផ្ទាល់នៅមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការសិក្សាដើម្បីរៀបចំបង្កើតនូវយន្តការសម្រាប់ផ្តល់មូលនិធិវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការបង្កើតយន្តការនេះ គឺដើម្បីផ្តល់ឱកាសឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពទទួលបាននូវមូលនិធិវិនិយោគពីប្រភពផ្សេងទៀត ដើម្បីប្រើប្រាស់សម្រាប់ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ ដែលជាតម្រូវការអាទិភាពរបស់ខ្លួន តែខ្លួនពុំមានធនធានគ្រប់គ្រាន់សម្រាប់អនុវត្ត ឬដែលមានលក្ខណៈជាគម្រោងអន្តររដ្ឋបាល (អន្តរ ឃុំ

សង្កាត់ អន្តរស្រុក ក្រុង អន្តរខេត្ត) ឬជាគម្រោងដែលត្រូវការអនុវត្តក្នុងរយៈពេលច្រើនឆ្នាំ ឬជាគម្រោងសម្រាប់បម្រើឱ្យគោលបំណងជាក់លាក់ដូចជា គម្រោងពាក់ព័ន្ធនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុជាដើម ។ល ។

**៤-) ប្រព័ន្ធគណនេយ្យភាព និងការពង្រឹងសមត្ថភាពក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ៖**

ក្រោមកិច្ចសហប្រតិបត្តិការជាមួយគម្រោងដែលគាំទ្រដោយសហភាពអឺរ៉ុប ហៅកាត់ថា EU-SPACE ដើម្បីលើកកម្ពស់សមត្ថភាពក្រុមប្រឹក្សាក្នុងការបំពេញការងារ គណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋតាមបែបប្រជាធិបតេយ្យ ក្រុមការងារក្រសួងមហាផ្ទៃបានរៀបចំសេចក្តីព្រាងឯកសារបច្ចេកទេសសម្រាប់ការអនុវត្តនីតិវិធីនៃកិច្ចប្រជុំ និងនីតិវិធីនៃការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាសាធារណៈរបស់ក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងគោលបំណងពង្រឹងប្រព័ន្ធគណនេយ្យភាពរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចំពោះប្រជាពលរដ្ឋមូលដ្ឋាន ។ សេចក្តីព្រាងឯកសារបច្ចេកទេសនេះ ត្រូវបានរៀបចំបញ្ចប់រួចរាល់ ហើយនឹងត្រូវដាក់ជូនស្ថាប័នពាក់ព័ន្ធដើម្បីពិភាក្សា និងពិគ្រោះយោបល់ មុននឹងដាក់ឱ្យប្រើប្រាស់ និងអនុវត្តជាផ្លូវការ ។

ជាមួយគ្នានេះដែរ ដើម្បីពង្រឹង និងជំរុញអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងស្វ័យភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសក្រុមប្រឹក្សាក្រុង ស្រុក គ.ជ.អ.ប ក៏បានចាត់ឱ្យលេខាធិការដ្ឋានធ្វើការសិក្សា និងរៀបចំសេចក្តីព្រាងគំរូនៃវិធានគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក។ គំរូនៃវិធានគ្រប់គ្រងរដ្ឋបាលក្រុង ស្រុកនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើច្បាប់ និងក្របខ័ណ្ឌគតិយុត្តដែលមានជាធរមាន ដោយធ្វើការបកស្រាយបន្ថែមឱ្យមានលក្ខណៈច្បាស់លាស់ សម្រាប់ធ្វើជាមូលដ្ឋាននៃការអនុវត្តជាក់ស្តែង ក្នុងន័យដើម្បីធានាថារដ្ឋបាលក្រុង ស្រុកត្រូវបានរៀបចំឡើង និងដំណើរការប្រព្រឹត្តទៅជានីតិបុគ្គលសាធារណៈដូចដែលបានកំណត់ដោយច្បាប់រៀបចំអង្គការ ។

ក្នុងការពង្រឹងភាពជាអ្នកតំណាង និងសម្លេងរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងឆ្នាំ២០១១ សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានកិច្ចសហការជាមួយ គ.ជ.អ.ប បានធ្វើការសិក្សា ពិគ្រោះយោបល់ ដើម្បីកំណត់ពីជម្រើសនានាសម្រាប់ការរៀបចំបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ។ ការសិក្សា និងពិគ្រោះយោបល់ដើម្បីកំណត់ជម្រើសទាំងនេះបានធ្វើឡើងតាមរយៈការធ្វើទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍ពីប្រទេសនានា កិច្ចប្រជុំពិភាក្សាផ្ទៃក្នុងនៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ និងតាមរយៈសន្និបាតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី២ដោយមានការចូលរួមពីតំណាងនៃក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ដែលបានរៀបចំឡើងនាខែសីហា ឆ្នាំ២០១១។

នៅឆ្នាំ២០១១នេះ គ.ជ.អ.ប ក៏បានចាត់ឱ្យលេខាធិការដ្ឋានបង្កើតនូវក្រុមការងារមួយដើម្បីទទួលខុសត្រូវក្នុងការរៀបចំនូវផែនការច្បាស់លាស់សម្រាប់ផ្តល់ការហ្វឹកហ្វឺនបំពាក់បំប៉នដល់ក្រុមប្រឹក្សានានា។ នៅ

ដើមឆ្នាំ២០១២នេះ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងត្រូវបានផ្តល់នូវមន្ត្រីជំនាញផ្នែកហិរញ្ញ មួយរូប ដោយផ្អែកលើល័ក្ខខ័ណ្ឌការងារ ដែលបានរៀបចំបញ្ចប់រួចរាល់នៅចុងឆ្នាំ២០១១នេះ។

**៥-) ការរៀបចំឡើងវិញនូវការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ៖**

ការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាសមាសធាតុដ៏សំខាន់មួយនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ គោលដៅចម្បងនៃការផ្ទេរមុខងារ និងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺដើម្បីបង្កិតសេវាឱ្យទៅកៀកជិតប្រជាពលរដ្ឋ មានតម្លាភាព និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ព្រមទាំងបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ ដែលជាការរួមចំណែកដ៏មានសារៈសំខាន់សម្រាប់កិច្ចអភិវឌ្ឍមូលដ្ឋាន។ ពាក់ព័ន្ធនឹងកិច្ចការរៀបចំឡើងវិញនូវការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងឆ្នាំ២០១១ គ.ជ.អ.ប បានសហការជាមួយក្រសួងពាក់ព័ន្ធសំខាន់ៗមួយចំនួន រួមមាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រួមជាមួយនឹងការគាំទ្រពីដៃគូអភិវឌ្ឍន៍នានា ធ្វើការសិក្សា និងរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណងកំណត់គោលការណ៍សំខាន់ៗ និងកិច្ចដំណើរការទូទៅនៃការរៀបចំផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យកិច្ចដំណើរការផ្ទេរមុខងារ និងធនធាននេះប្រព្រឹត្តទៅនៅក្នុងលក្ខណៈជាប្រព័ន្ធ ជាជំហានៗ និងដោយប្រុងប្រយ័ត្ន។ សេចក្តីព្រាងអនុក្រឹត្យនេះត្រូវបានរៀបចំឡើងដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាមូលដ្ឋាននានា ដូចជាក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលបានផ្តល់ការណែនាំអំពីទស្សនៈទានសំខាន់ៗទាក់ទងនឹងការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវា និងការអភិវឌ្ឍនៅមូលដ្ឋាន ច្បាប់រៀបចំអង្គការដែលបានចង្អុលបង្ហាញអំពីក្របខ័ណ្ឌច្បាប់ និងគោលការណ៍ចម្បងៗសម្រាប់ការអនុវត្ត និងកម្មវិធីជាតិដែលបានកំណត់អំពីវិធីសាស្ត្រ និងដំណាក់កាលនានាក្នុងការរៀបចំ និងការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងកិច្ចដំណើរការរៀបចំសេចក្តីព្រាងអនុក្រឹត្យនេះ ក្រៅពីផ្អែកលើក្របខ័ណ្ឌគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត គ.ជ.អ.ប ក៏បានការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ដ៏ទូលំទូលាយមួយនាថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលមានការចូលរួមពីតំណាងក្រសួង ស្ថាប័ននៅថ្នាក់ជាតិ តំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងតំណាងអង្គការសង្គមស៊ីវិល ដើម្បីប្រមូលបទពិសោធន៍ ធាតុចូល និងអនុសាសន៍ពីអ្នកពាក់ព័ន្ធទាំងនោះ។ បន្ទាប់ពីសិក្ខាសាលាពិគ្រោះយោបល់ សេចក្តីព្រាងអនុក្រឹត្យក៏ត្រូវបានពិភាក្សាក្នុងកិច្ចប្រជុំនៃអនុគណៈកម្មាធិការមុខងារ និងធនធាន ដែលបានរៀបចំឡើងនាថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១១។ បច្ចុប្បន្ននេះ សេចក្តីព្រាងអនុក្រឹត្យនេះកំពុងត្រូវបានដាក់ជូន គ.ជ.អ.ប ដើម្បីពិនិត្យ មុននឹងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងអនុម័តនៅដើមឆ្នាំ២០១២។

សេចក្តីព្រាងអនុក្រឹត្យស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ បានកំណត់នូវជំហានសំខាន់ៗចំនួនពីរនៃកិច្ចដំណើរការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ពោលគឺការរៀបចំបញ្ជីវិភាគមុខងារ និងការពិនិត្យមើលឡើងវិញនូវមុខងារ និងធនធានដែលត្រូវផ្ទេរ។ ក្នុងជំហានទាំងពីរនេះ តម្រូវឱ្យមានសេចក្តីណែនាំបច្ចេកទេសលម្អិតសម្រាប់ណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនានាដើម្បីអនុវត្ត។ ពាក់ព័ន្ធនឹងកិច្ចការនេះ គ.ជ.អ.ប ក៏បានត្រៀមរៀបចំនូវសេចក្តីព្រាងសេចក្តីណែនាំស្តីពីការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ននានា ដើម្បីត្រៀមលក្ខណៈជាស្រេច សម្រាប់ការអនុវត្តបន្ទាប់ពីសេចក្តីព្រាងអនុក្រឹត្យស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ដោយរាជរដ្ឋាភិបាល។

**៦-) ការរៀបចំប្រព័ន្ធអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ៖**

ការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាលក្ខខណ្ឌចាំបាច់ក្នុងការកំណត់ពីភាពជោគជ័យនៃកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្នុងបរិបទនៃកម្មវិធីជាតិ ការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅលើការអភិវឌ្ឍសមត្ថភាពបុគ្គល និងការអភិវឌ្ឍសមត្ថភាពស្ថាប័នដើម្បីបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ក្នុងឆ្នាំ២០១១ ពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធអភិវឌ្ឍសមត្ថភាពនេះ លទ្ធផលសំខាន់ៗដែលសម្រេចបានគឺការរៀបចំចងក្រងទិន្នន័យដើមគ្រាសម្រាប់ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ការពិនិត្យឡើងវិញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំសេចក្តីព្រាងស្តីពីផែនការអភិវឌ្ឍស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ និងការសិក្សាអំពីលទ្ធភាពនៃការបង្កើតនូវវិទ្យាស្ថានបណ្តុះបណ្តាលមួយ សម្រាប់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនឹងអាចក្លាយទៅជាមជ្ឈមណ្ឌលដ៏សំខាន់ក្នុងការផ្តល់នូវចំណេះដឹងជាមូលដ្ឋាននៅលើគ្រប់វិស័យ និងផ្តល់នូវការបញ្ជាក់អះអាងពីកម្រិតសមត្ថភាពរបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិនានា។ ជារួមមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិចំនួនប្រមាណជាង៧.០០០នាក់ត្រូវបានបណ្តុះបណ្តាលតាមរយៈវគ្គណែនាំតម្រង់ទិសសិក្ខាសាលានានា។

**៧-) ការរៀបចំយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ៖**

ការបញ្ជ្រាបយេនឌ័រគឺជាបញ្ហាអន្តរវិស័យដ៏សំខាន់ ដែលបានកំណត់ទាំងនៅក្នុងកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផអ៣នៃកម្មវិធីជាតិ។ ការបញ្ជ្រាបយេនឌ័រគឺជាការខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ជាពិសេសក្នុងតួនាទីធ្វើការសម្រេចចិត្ត អភិបាលកិច្ច និងក្នុងការធ្វើឱ្យស្ត្រីទទួលបានសេវាសាធារណៈផ្សេងៗកាន់តែប្រសើរ។ ក្នុងឆ្នាំ២០១១នេះ សមិទ្ធផលសំខាន់ៗពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័ររួមមាន ៖ ១).បានដាក់បញ្ចូលការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ផអ៣ទៅក្នុងបរិបទនៃអនុកម្មវិធីនីមួយៗ។ មានន័យថាក្រសួង និងស្ថាប័នដែលទទួលបន្ទុកអនុវត្តអនុកម្មវិធីនីមួយៗនៃផអ៣មានតួនាទីផ្តួចផ្តើម ដឹកនាំ និងទទួលខុសត្រូវលើកិច្ចការបញ្ជ្រាប

យេនឌ័រចាប់តាំងពីដំណាក់កាលនៃការរៀបចំផែនការសកម្មភាព និងថវិកា និងនៅក្នុងកំឡុងពេលនៃការអនុវត្តសកម្មភាពជាក់ស្តែង ។ ដោយឡែក ក្រសួងកិច្ចការនារីជាអ្នកផ្តល់ជំនួយបច្ចេកទេស និងផ្តល់ការគាំទ្រនានាតាមការស្នើសុំ និងតាមការចាំបាច់ ។ ២).បានសិក្សាវាយតម្លៃដើម្បីកំណត់ពីតម្រូវការបណ្តុះបណ្តាលស្តីពីយេនឌ័រតាមអនុកម្មវិធីនីមួយៗ និងពីថ្នាក់ដឹកនាំជាស្ត្រីនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីត្រៀមសម្រាប់ការបណ្តុះបណ្តាលក្នុងឆ្នាំ២០១២ ។

ចំពោះសកម្មភាពនៅថ្នាក់ក្រោមជាតិ គ.ជ.អ.ប បានផ្តល់ថវិកាមួយចំនួនទៅឱ្យមន្ទីរកិច្ចការនារីទាំង២៤ រាជធានី ខេត្ត ក្នុងការបំពេញមុខងារបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី តាមរយៈគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ សង្កាត់ ។

**៨-) ការកែសម្រួលរចនាសម្ព័ន្ធលេខាធិការដ្ឋាន គ.ជ.អ.ប ៖**

ការវិវត្តនៃកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានឈានចូលដំណាក់កាលកាន់តែស៊ីជម្រៅ រសើប និងសាំញ៉ាំ ដែលតម្រូវឱ្យមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវការស្រុះស្រួល និងឯកភាពគ្នានៅក្នុងរាជរដ្ឋាភិបាលទាំងមូលចំពោះកិច្ចដំណើរការកំណែទម្រង់នេះ ។ ឆ្លើយតបទៅនឹងស្ថានភាពនេះ ផអ៣នៃកម្មវិធីជាតិបានរៀបចំឡើងដោយកំណត់ឱ្យមានអនុកម្មវិធីចំនួន០៦ ដែលត្រូវដាក់ឱ្យអនុវត្តក្រោមបេសកកម្ម និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នសំខាន់ៗចំនួន០៦ផ្សេងគ្នា ។ ការរៀបចំបែបនេះ ក្នុងគោលបំណងលើកកម្ពស់ការចូលរួម ការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រី ការអភិវឌ្ឍសមត្ថភាពរបស់ស្ថាប័ន ការពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និងការកាត់បន្ថយនូវហានិភ័យនៅពេលដែលពុំមានការគាំទ្រកិច្ចប្រតិបត្តិការពីខាងក្រៅ ។ ពាក់ព័ន្ធនឹងបញ្ហានេះ ផអ៣ក៏តម្រូវឱ្យធ្វើការកែសម្រួលតួនាទី និងរចនាសម្ព័ន្ធនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីធានាដល់ការរ៉ាប់រងបាននូវបន្ទុកការងារនានា ដែលជាបេសកកម្មរបស់ គ.ជ.អ.ប ក្នុងការដឹកនាំ និងសម្របសម្រួលកិច្ចដំណើរការកំណែទម្រង់ក្នុងដំណាក់កាលដ៏រសើប និងសាំញ៉ាំនេះ ។

ជាលទ្ធផល ក្នុងឆ្នាំ២០១១នេះ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធរាជរដ្ឋាភិបាល បានសម្រេចដាក់ចេញនូវអនុក្រឹត្យស្តីពីការកែសម្រួលមាត្រាពាក់ព័ន្ធមួយចំនួននៃអនុក្រឹត្យលេខ ២៣ អ ន ក្រ .បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងគោលបំណងកែសម្រួលតួនាទី និងរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ។ អនុក្រឹត្យនេះត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនាខែតុលា ឆ្នាំ២០១១ ។ ផ្អែកលើអនុក្រឹត្យនេះ គ.ជ.អ.ប ក៏បានរៀបចំប្រកាសស្តីពីតួនាទីលម្អិត និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន គ.ជ.អ.ប នាខែធ្នូ ឆ្នាំ២០១១ ។

## ខ-) ការរៀបចំ និងអនុវត្តកម្មវិធី

ការរៀបចំ និងអនុវត្តកម្មវិធីគឺជាកត្តាសំខាន់សម្រាប់ការពង្រឹងសមត្ថភាពស្ថាប័នថ្នាក់ជាតិក្នុងការគាំទ្រដល់ការអនុវត្តគោលនយោបាយ ចក្ខុវិស័យ និងសកម្មភាពនានាដែលបានកំណត់ក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការពង្រឹងស្ថាប័នថ្នាក់ជាតិសម្រាប់គាំទ្រកំណែទម្រង់នេះ ពុំមែនធ្វើឡើងតែក្នុងអំឡុងពេលនៃកិច្ចដំណើរការផ្ទេរមុខងារ ការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធានឱ្យទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនោះឡើយ ពោលគឺត្រូវរៀបចំស្ថាប័នឱ្យបានរឹងមាំសម្រាប់ធ្វើការជាប្រចាំជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ នៅក្នុងឆ្នាំ២០១១ គ.ជ.អ.ប បានខិតខំប្រឹងប្រែងដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ក្នុងការរៀបចំផអ៣នៃកម្មវិធីជាតិ គួបផ្សំជាមួយនឹងការរៀបចំ និងសម្របសម្រួលការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១១នៃផអ៣ ដើម្បីឆ្លងកាត់នូវដំណាក់កាលអន្តរកាលដ៏លំបាកស្មុគស្មាញនាចុងឆ្នាំ២០១០ និងឆ្នាំ២០១១ ព្រមទាំងសម្រេចបាននូវសមិទ្ធផលគួរជាមោទនៈដូចខាងក្រោម៖

**១-) ការរៀបចំផអ៣ និងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១១នៃផអ៣ ៖**

ក្នុងគោលបំណងលើកកម្ពស់ការចូលរួម និងការទទួលខុសត្រូវពីគ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលនៅក្នុងដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផ្អែកលើយុទ្ធសាស្ត្រដែលកំណត់ថា "ជាដំណើរការកំណែទម្រង់ដែលតម្រូវឱ្យមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលទាំងមូល" ផអ៣ដំបូងនៃកម្មវិធីជាតិ ត្រូវបានតាក់តែងឡើងដោយកំណត់ឱ្យមានអនុកម្មវិធីចំនួន០៦ ដែលទទួលខុសត្រូវអនុវត្តដោយក្រសួង ស្ថាប័នចំនួន៦ផ្សេងៗគ្នា។ ពោលគឺ៖

- **អនុកម្មវិធីទី១** ទទួលខុសត្រូវអនុវត្តដោយលេខាធិការដ្ឋាន គ.ជ.អ.ប ដែលផ្តោតលើការរៀបចំគោលនយោបាយ និងការសម្របសម្រួលកម្មវិធី
- **អនុកម្មវិធីទី២** ទទួលខុសត្រូវអនុវត្តដោយក្រសួងមហាផ្ទៃ ដែលផ្តោតទៅលើការរៀបចំ និងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- **អនុកម្មវិធីទី៣** ទទួលខុសត្រូវអនុវត្តដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលផ្តោតលើការរៀបចំប្រព័ន្ធគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- **អនុកម្មវិធីទី៤** ទទួលខុសត្រូវអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលផ្តោតជាសំខាន់លើធនធានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- **អនុកម្មវិធីទី៥** ទទួលខុសត្រូវអនុវត្តដោយក្រសួងផែនការ ដែលផ្តោតលើការរៀបចំប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- **អនុកម្មវិធីទី៦** ទទួលខុសត្រូវអនុវត្តដោយសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ ដែលផ្តោតជាសំខាន់ទៅលើការបង្កើតសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា។

ទោះបីជាឯកសារផអ៣ ត្រូវបានអនុម័តជាគោលការណ៍ដោយ គ.ជ.អ.ប នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ក៏ដោយ ក៏ប៉ុន្តែដើម្បីធានាដល់ការកៀរគរការគាំទ្រពីដៃគូអភិវឌ្ឍន៍ ឯកសារផអ៣នេះត្រូវបានដាក់ឱ្យធ្វើការវាយតម្លៃរួមគ្នាដោយដៃគូអភិវឌ្ឍន៍។ ការវាយតម្លៃរួមគ្នានេះត្រូវបានចាប់ផ្តើមពីដើមខែកុម្ភៈ និងបញ្ចប់នៅដើមខែមីនាឆ្នាំ២០១១ ដោយទទួលបាននូវលទ្ធផលជាវិជ្ជមាន រួមជាមួយនឹងអនុសាសន៍សំខាន់ៗមួយចំនួនដែលផ្តោតលើការកែលំអបន្ថែមនូវយុទ្ធសាស្ត្របញ្ច្រាបយេនឌ័រ យុទ្ធសាស្ត្រនៃការផ្ទេរចំណេះដឹង ការរៀបចំបន្ថែមនូវក្របខ័ណ្ឌគណនេយ្យភាពសង្គម និងការកែតម្រូវថវិកាប៉ាន់ស្មានរបស់ផអ៣។

ជាមួយនឹងដំណើរការវាយតម្លៃផអ៣ គ.ជ.អ.ប ក៏បានសហការ និងពិគ្រោះយោបល់យ៉ាងលម្អិតជាច្រើនលើកជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១១ ដែលជាការចាប់ផ្តើមនៃការអនុវត្តផអ៣នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នេះ មានថវិកាសរុបប្រមាណ**៧៣**លានដុល្លារ (ដោយមិនគតិបញ្ចូលនូវថវិការាជធានី ខេត្ត) ដែលក្នុងនោះថវិកាចំនួនប្រមាណ**៦៦,៣**លានដុល្លារត្រូវបានទទួលសន្យាផ្តល់ឱ្យ ដូចមានបង្ហាញជូនក្នុងតារាងខាងក្រោម៖

| ប្រភព | ចំនួន (US$) | % | | ប្រភព | ចំនួន | % |
|---|---|---|---|---|---|---|
| **ថវិកាជាតិ** | | | | ការគាំទ្រមិនមែនជាថវិកា (In kind)[4] | | |
| ថវិកាក្រុង ស្រុក | 11.000.000 | | | WB-OWSO | 1.667.602 | |
| មូលនិធិឃុំ សង្កាត់ | 38.300.000 | | | UNDP/DDLG-PSDD | 1.444.050 | |
| គម្រោងកាវិ. ច្រកចេញចូលតែមួយ | 788.740 | | | JICA-PILAC2 | 210.624 | |
| **សរុបរង** | **$50.088.740** | **76** | | UNICEF | 60.000 | |
| **ថវិកាសម្រាប់គាំទ្រប្រតិបត្តិការកម្មវិធី** | | | | ADB | 150.000 | |
| ស៊ុយអែត-ស៊ីដា (Sweden) | 9.459.560 | | | EU-SPACE | 148.000 | |
| ដានីដា (Danida) | 1.905.678 | | | UNCDF | 90.000 | |
| UNICEF | 1.013.477 | | | UNFPA | 65.000 | |
| UNDP/PSDD | 89.132 | | | **សរុបរង** | **$3.784.276** | 5 |
| **សរុបរង** | **$12.467.847** | **19** | | **សរុបរួម** | **$66.340.863** | **100** |

[4] ជាការគាំទ្រដោយគម្រោង ឬកម្មវិធីដោយឡែកៗដល់ការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំរបស់ គ.ជ.អ.ប តែមិនបានផ្តល់ថវិកាសម្រាប់ការអនុវត្តសកម្មភាពដែលខ្លួនគាំទ្រនោះ មកស្ថិតក្រោមការគ្រប់គ្រងនិងចាត់ចែងដោយ គ.ជ.អ.បឡើយ។

ក្នុងការរៀបចំការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១១ គ.ជ.អ.ប ក៏បានរៀបចំអនុស្សរណៈស្តីពីការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១១ ជាមួយអនុកម្មវិធីទាំង៦ និងជាមួយរាជធានី ខេត្តទាំង២៤តំណាងឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ ក្នុងឆ្នាំ២០១១ គ.ជ.អ.ប ក៏បានរៀបចំអនុស្សរណៈជាមួយក្រសួង ស្ថាប័នចំនួន០៦ផ្សេងទៀត គឺក្រសួងកិច្ចការនារីដើម្បីឱ្យផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់អនុកម្មវិធីទាំង៦លើការងារបញ្ជ្រាបយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី និងក្រសួងអប់រំយុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីបន្តគាំទ្រកិច្ចដំណើរការរៀបចំការផ្ទេរមុខងារ និងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានទឹកប្រាក់សរុបចំនួន២៣៤.០០០ដុល្លារ។

ការចំណាយសរុបលើការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១១ តាមអនុកម្មវិធីនីមួយៗ ដោយគិតតែចំពោះថវិកាសម្រាប់គាំទ្រប្រតិបត្តិការកម្មវិធី មានចំនួនប្រមាណ៦៤,៥%នៃថវិកាគ្រោងសរុបតាមអនុកម្មវិធីនីមួយៗ។ តារាងចំណាយលើប្រតិបត្តិការតាមអនុកម្មវិធីនីមួយៗមានដូចខាងក្រោម៖

| អនុកម្មវិធី | ថវិកាគ្រោង (US$) | ថវិកាផ្តល់តាមរយៈ | | ចំណាយ | |
|---|---|---|---|---|---|
| | | ការគាំទ្រមិនមែនជាថវិកា | លេខាធិការដ្ឋាន | ចំនួន (US$) | % |
| អនុកម្មវិធីទី១ | 13.118.086 | 1.232.400 | 11.885.686 | 9.761.954 | 74,42 |
| អនុកម្មវិធីទី២ | 5.690.124 | 2.712.632 | 2.977.492 | 3.162.859 | 55,59 |
| អនុកម្មវិធីទី៣ | 101.729 | 0 | 101.729 | 31.115 | 30,59 |
| អនុកម្មវិធីទី៤ | 1.201.523 | 129.860 | 1.071.663 | 451.552 | 37,58 |
| អនុកម្មវិធីទី៥ | 651.377 | 250.624 | 400.753 | 201.348 | 30,91 |
| អនុកម្មវិធីទី៦ | 475.313 | 247.500 | 227.813 | 88.016 | 18,52 |
| **សរុប** | **21.238.152** | **4.573.016** | **16.665.136** | **13.696.842** | **64.49** |

ក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១១ ក៏បានកំណត់ នូវចំណុចដៅសំខាន់ៗចំនួន១០សម្រាប់ ធ្វើជាមូលដ្ឋានក្នុងការវាស់វែងវឌ្ឍនភាពក្នុងពេលអនុវត្តតាមពេលវេលាកំណត់ផងដែរ។ ស្ថានភាពនៃការអនុវត្ត និងសម្រេចបានតាមចំណុចដៅសំខាន់ៗទាំង១០នេះមានបង្ហាញនៅក្នុងតារាងដូចខាងក្រោម៖

| ពេលវេលា | ចំណុចដៅ | ស្ថានភាពនៃការអនុវត្ត |
|---|---|---|
| ត្រីមាសទី១ | ១. ច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុម័ត | បានអនុម័ត និងដាក់ឱ្យប្រើប្រាស់នៅក្នុងត្រីមាសទី២ |
| ត្រីមាសទី២ | ២. បុគ្គលិកកិច្ចសន្យា និងទីប្រឹក្សានៅថ្នាក់ក្រុង ស្រុក(៣៨៦រូប) និងនៅថ្នាក់រាជធានី ខេត្ត(២៤០រូប) ត្រូវបានជ្រើសរើសឱ្យបម្រើការងារ និងទទួលបានការបណ្ដុះបណ្ដាលតម្រង់ទិសអំពីការងាររបស់ខ្លួន | បានបញ្ចប់នៅត្រីមាសទី២ |
| | ៣. ការរៀបចំយន្តការផ្ដល់ហិរញ្ញប្បទានរួមរបស់ដៃគូអភិវឌ្ឍសម្រាប់គាំទ្រដល់កម្មវិធីត្រូវបានរៀបចំ និងឯកភាព និងជម្រើសនានាសម្រាប់ការផ្ដល់ហិរញ្ញប្បទានគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ក្នុងរយៈពេលខ្លី និងរយៈពេលវែងត្រូវបានសិក្សា និងឯកភាពដោយរាជរដ្ឋាភិបាល | បានបញ្ចប់នៅត្រីមាសទី២ |
| ត្រីមាសទី៣ | ៤. ក្រុង ស្រុកទាំង១៨៥ បានរៀបចំ និងដាក់ស្នើ និងអនុម័តថវិកាមូលនិធិ ក្រុង ស្រុករបស់ខ្លួនសម្រាប់ការអនុវត្តពីខែ មិថុនា ដល់ខែធ្នូឆ្នាំ២០១១ | ចំណុចដៅនេះមិនទាន់បានសម្រេច ដោយសារការយឺតយ៉ាវនៃការរៀបចំ ប្រព័ន្ធផ្ទេរមូលនិធិ និងគ្រប់គ្រងហិរញ្ញវត្ថុ ក្រុង ស្រុក |
| | ៥. ការបណ្ដុះបណ្ដាលដល់ក្រុង ស្រុកទាំងអស់ស្ដីពី កិច្ចប្រតិបត្តិការជាមូលដ្ឋានត្រូវបានរៀបចំ | សៀវភៅបណ្ដុះបណ្ដាលមិនទាន់ត្រូវបានរៀបចំបញ្ចប់ ។ ការបណ្ដុះបណ្ដាលស្ដីពី ការគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក មិនទាន់អាចរៀបចំបាន ដោយសារជាប់ពាក់ព័ន្ធ នឹងការរៀបចំមូលនិធិក្រុង ស្រុក និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក |
| ត្រីមាសទី៤ | ៦. មូលនិធិប្រមាណ៤លានដុល្លារពីដៃគូអភិវឌ្ឍន៍ត្រូវបានផ្ទេរទៅក្នុងមូលនិធិក្រុង ស្រុក និងត្រូវបានផ្ទេរឱ្យទៅក្រុង ស្រុក | មិនទាន់ផ្ទេរទៅបានដោយសារមិនទាន់មានប្រព័ន្ធផ្ទេរ និងប្រព័ន្ធគ្រប់គ្រងមូលនិធិក្រុង ស្រុក |
| | ៧. ឯកសារគោលនយោបាយស្ដីពីប្រភពចំណូលផ្ទាល់នៅមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ (ចំណូលពីពន្ធ និងមិនមែនសារពើពន្ធ) | បានត្រៀមរៀបចំការសិក្សាជំហានដំបូង |
| | ៨. សេចក្ដីព្រាងរបាយការណ៍ស្ដីពីការអនុវត្តការងាររបស់ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំដោយផ្អែកលើការធ្វើអធិការកិច្ចលើការអនុវត្តតាម និងការសិក្សាវាយតម្លៃសមត្ថភាព | កិច្ចដំណើរការសិក្សាវាយតម្លៃសមត្ថភាពកំពុងត្រូវបានអនុវត្ត ។ ការសិក្សាអង្កេតស្ដីពីអភិបាលកិច្ចមូលដ្ឋានក៏កំពុងត្រូវបានអនុវត្ត |
| | ៩. ការសាកល្បងលើការផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងឯកភាពដោយអ្នកពាក់ព័ន្ធ | សេចក្ដីព្រាងអនុក្រឹត្យស្ដីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានទៅឱ្យដល់រដ្ឋ |

| | | |
|---|---|---|
| | | បាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងឯកភាពដោយអនុគណៈកម្មាធិការមុខងារ និងធនធាន |
| | ១០. នីតិវិធីនៃការពង្រឹងសមត្ថភាពដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ អ្នកហ្វឹកហ្វឺនត្រូវបានជ្រើសរើស និងការផ្តល់ការបណ្តុះបណ្តាលតម្រង់ទិសដល់អ្នកហ្វឹកហ្វឺនទាំងនោះត្រូវបានរៀបចំ | កិច្ចដំណើការជ្រើសអ្នកហ្វឹកហ្វឺនកំពុងត្រូវបានអនុវត្ត។ |

**២-) សង្ខេបលទ្ធផលនៃការអនុវត្តអនុកម្មវិធីទី១**

ផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី១ ផ្តោតជាសំខាន់ទៅលើការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការអនុវត្តកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានកំណត់ដោយច្បាប់រៀបចំអង្គការ ការជំរុញនូវកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ការសម្របសម្រួល ការគ្រប់គ្រង ការតាមដានការអនុវត្តកម្មវិធី និងការរៀបចំប្រព័ន្ធប្រឹក្សាយោបល់ និងអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ លទ្ធផលសង្ខេបនៃការអនុវត្តផែនការសម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី១នេះ មានដូចខាងក្រោម៖

**២.១) ការរៀបចំលិខិតបទដ្ឋានគតិយុត្ត៖** ក្នុងចំណោមលិខិតបទដ្ឋានគតិយុត្តចំនួនប្រមាណ៣៥ដែលបានកំណត់នៅក្នុងផែនការសកម្មភាពឆ្នាំ២០១១ មានលិខិតបទដ្ឋានចំនួន១៤ត្រូវបានរៀបចំបញ្ចប់ និងដាក់ឱ្យអនុវត្ត លិខិតបទដ្ឋានចំនួន០៩កំពុងត្រូវបានរៀបចំជាសេចក្តីព្រាង និងលិខិតបទដ្ឋានចំនួន១២ផ្សេងទៀតស្ថិតនៅក្នុងដំណាក់កាលនៃការចាប់ផ្តើមសិក្សា និងបន្តរៀបចំនៅក្នុងឆ្នាំ២០១២។

**២.២) ការជំរុញនូវការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ៖** បានធ្វើការសិក្សាអំពីតម្រូវការនៃការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងបានរៀបចំកិច្ចដំណើរការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរួមទាំងដៃគូអភិវឌ្ឍន៍ តាមរយៈកិច្ចប្រជុំ និងសិក្ខាសាលាថ្នាក់ជាតិក្នុងការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ សេចក្តីព្រាងអនុក្រឹត្យត្រូវបានរៀបចំ និងបានដាក់ជូនអនុគណៈកម្មាធិការមុខងារ និងធនធានដើម្បីពិនិត្យ ពិភាក្សា និងឯកភាព។ បច្ចុប្បន្ន សេចក្តីព្រាងអនុក្រឹត្យនេះកំពុងត្រូវបានដាក់ជូន គ.ជ.អ.ប ពិនិត្យ និងផ្តល់យោបល់ មុននឹងបញ្ជូនទៅសុំការអនុម័តពីគណៈរដ្ឋមន្ត្រី។ ក្រៅពីការរៀបចំសេចក្តីព្រាងអនុក្រឹត្យនេះ សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំបញ្ជីវិភាគមុខងារក៏ត្រូវបានរៀបចំផងដែរ សម្រាប់ផ្តល់ការណែនាំដល់ក្រសួង ស្ថាប័ននានាក្នុងការអនុវត្តកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ បន្ទាប់ពីសេចក្តីព្រាងអនុក្រឹត្យត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល។

**២.៣) ការសម្របសម្រួល ការគ្រប់គ្រង និងការតាមដានការអនុវត្តកម្មវិធី៖** បានរៀបចំអនុស្សរណៈសម្រាប់ការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១១ ជាមួយអនុកម្មវិធីទាំងប្រាំមួយ និងរាជធានី ខេត្តទាំង២៤តំណាងឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងបានរៀបចំអនុស្សរណៈជាមួយក្រសួង ស្ថាប័ន ចំនួន០៦ផ្សេងទៀត ដើម្បីបន្តដំណើរការអនុវត្តសកម្មភាពពាក់ព័ន្ធនានាក្រោមក្របខ័ណ្ឌនៃផអ៣។ ទីប្រឹក្សា និងមន្ត្រីកិច្ចសន្យាសរុបចំនួន៦០៨រូបត្រូវបានជ្រើសរើស និងតែងតាំងឱ្យទៅបម្រើការងារទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិតាមការកំណត់។ មន្ត្រីបម្រើការងារក្រោមក្របខ័ណ្ឌនៃប្រព័ន្ធចំណាយប្រតិបត្តិការអាទិភាពចំនួន១.៤១៨រូបត្រូវបានជ្រើសរើស និងតែងតាំងឱ្យទៅបម្រើការងារក្រោមក្របខ័ណ្ឌនៃផអ៣ ដែលក្នុងនោះនៅថ្នាក់ជាតិមានចំនួន១១១រូប និងនៅថ្នាក់ក្រោមជាតិចំនួន១.៣០៧រូប។ ការបណ្តុះបណ្តាលតម្រង់ទិសដល់ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យាទាំងអស់ក៏ត្រូវបានរៀបចំ ដោយផ្តោតជាសំខាន់ទៅលើទិដ្ឋភាពធំៗចំនួន៣គឺ ក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ ក្របខ័ណ្ឌនៃការអនុវត្ត និងប្រព័ន្ធនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងប្រព័ន្ធរបាយការណ៍នៃការអនុវត្តផែនការសកម្មភាព និងថវិកាក្រោមក្របខ័ណ្ឌនៃផអ៣ ក៏ត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់។ រចនាសម្ព័ន្ធលេខាធិការដ្ឋាន គ.ជ.អ.ប ក៏កំពុងត្រូវបានរៀបចំឡើងវិញ ដោយផ្អែកលើអនុក្រឹត្យដែលបានកែសម្រួល និងប្រកាសស្តីពីការកែសម្រួលរចនាសម្ព័ន្ធលេខាធិការដ្ឋាន គ.ជ.អ.ប។

**២.៤) ការរៀបចំប្រព័ន្ធប្រឹក្សាយោបល់ និងពង្រឹងសមត្ថភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ៖** ការសិក្សាលើការអនុវត្តកម្មវិធីសាកល្បងនៃការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សា ដែលគាំទ្រដោយ EU-SPACE ត្រូវបានរៀបចំ ដើម្បីកំណត់រកជម្រើសសមស្របសម្រាប់ការរៀបចំប្រព័ន្ធ ដើម្បីពង្រីកកម្មវិធីពង្រឹងសមត្ថភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់។ សេចក្តីព្រាងនៃប្រព័ន្ធពង្រឹងសមត្ថភាពក្រុមប្រឹក្សាត្រូវបានរៀបចំ។ ទីប្រឹក្សា និងមន្ត្រីកិច្ចសន្យាសម្រាប់គាំទ្រដល់ការអនុវត្តប្រព័ន្ធនេះ ក៏កំពុងត្រូវបានជ្រើសរើសផងដែរ។

ការចំណាយលើការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី១ មានសង្ខេបនៅក្នុងតារាងខាងក្រោម៖

| សមាសភាគ | ថវិកាគ្រោង($) | ថវិកាចំណាយ($) | % |
|---|---|---|---|
| ការរៀបចំលិខិតបទដ្ឋានគតិយុត្ត | 1.562.907 | $1.132.491 | 72,46 |
| ការជំរុញនូវការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ | $109.000 | $55.488 | 50,91 |
| ការសម្របសម្រួល ការគ្រប់គ្រង និងការតាមដានការអនុវត្តកម្មវិធី | $9.699.279 | $8.338.505 | 85,97 |
| ការរៀបចំប្រព័ន្ធប្រឹក្សាយោបល់ និងពង្រឹងសមត្ថភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | $1.746.900 | $235.469 | 13,48 |
| **សរុប** | **$13.118.086** | **$9.761.954** | **74,42** |

**៣-) សង្ខេបលទ្ធផលការអនុវត្តអនុកម្មវិធីទី២**

ផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី២ ផ្តោតជាសំខាន់ទៅលើការរៀបចំឡើងវិញនូវបុគ្គលិក និងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ការត្រួតពិនិត្យមើល ការពិនិត្យនីត្យានុកូលភាព ការងារអត្រានុកូលដ្ឋាន និងការងារគណនេយ្យភាព ការរៀបចំល័ក្ខខ័ណ្ឌធ្វើការងារនិងផ្តល់សម្ភារៈបរិក្ខារ អាគារសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការគ្រប់គ្រងសេវារដ្ឋបាល និងការគាំទ្រ ដើម្បីបង្កលក្ខណៈឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចបំពេញការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព មានគណនេយ្យភាព និងមានសមត្ថភាពក្នុងការទទួលខុសត្រូវលើការងារតាមដាន និងត្រួតពិនិត្យមើល និងអនុវត្តមុខងារផ្សេងទៀតដែលត្រូវបានផ្ទេរទៅឱ្យដោយថ្នាក់ជាតិ។ លទ្ធផលសង្ខេបនៃការអនុវត្តផែនការសម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី១នេះ មានដូចខាងក្រោម៖

**៣.១.)ការរៀបចំបុគ្គលិក និងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ៖** នៅថ្នាក់រាជធានី ខេត្ត មន្ត្រីរាជការរដ្ឋបាលចំនួន២.៧៤0នាក់ (ស្រី៧១៨នាក់) ត្រូវបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលរាជធានីខេត្ត និងអភិបាលរងខេត្តចំនួន១៧នាក់ត្រូវបានតែងតាំងបន្ថែម។ នៅថ្នាក់ក្រុង ស្រុក ខណ្ឌ មន្ត្រីរាជការរដ្ឋបាលចំនួន៥.២៤៦នាក់ (ស្ត្រី១.០៦៩ នាក់) ត្រូវបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ អភិបាលរងក្រុង ស្រុកចំនួន១០១នាក់ត្រូវបានតែងតាំងបន្ថែម។ ខណ្ឌចំនួន១ ឃុំសង្កាត់ចំនួន១២ និងភូមិចំនួន១៤៤ត្រូវបានសិក្សា និងបង្កើតឡើង។

**៣.២.)ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** វគ្គបណ្តុះបណ្តាលរយៈពេល៣ថ្ងៃស្តីពីតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់រដ្ឋបាលរាជធានីខេត្ត ក្រុងស្រុកខណ្ឌ, កម្មវិធីជាតិ និង ផអ៣ សម្រាប់គ្រូបង្គោលថ្នាក់ជាតិ គ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត និងបុគ្គលិករាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំឡើងដោយមានអ្នកចូលរួមសរុបចំនួន៧.0៩១នាក់ (ស្រី១.៧៤៤នាក់ ស្មើនឹង២៥%)។ ក្រុមអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិនៃអនុកម្មវិធីទី២ចំនួន២៥នាក់ (ស្រី៥នាក់ ស្មើនឹង២0%) ត្រូវបានបង្កើតឡើង និងបានទទួលការបណ្តុះបណ្តាលអំពីជំនាញអភិវឌ្ឍន៍សមត្ថភាពរយៈពេល១0ថ្ងៃ និងអំពីទស្សនទានយេនឌ័ររយៈពេល៣ថ្ងៃ។ មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធថ្មីចំនួន៣១នាក់ (ស្រី២នាក់) ត្រូវបានបណ្តុះបណ្តាលរយៈពេល៥ថ្ងៃស្តីពីមូលដ្ឋានគ្រឹះនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ សង្កាត់។ សៀវភៅណែនាំលម្អិតស្តីពីតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ត្រូវបានរៀបចំឡើង និងវគ្គបណ្តុះបណ្តាលរយៈពេល២ថ្ងៃ ស្តីពីសៀវភៅណែនាំនេះ សម្រាប់គ្រូបង្គោលថ្នាក់ជាតិ គ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំឡើង ដោយមានសិក្ខាកាមចូលរួមសុបចំនួន៧.៨៦៨នាក់ (ស្រី៣.៧0៣នាក់ ស្មើ៤៧%)។ ក្រៅពីការបណ្តុះបណ្តាលខាងលើ ក្រោមកិច្ចសហការជាមួយអង្គការGIZ សេចក្តីព្រាងសេចក្តីណែនាំសម្រាប់ប្រតិបត្តិ

ការការងារនៅថ្នាក់ក្រុង ស្រុក ក៏ត្រូវបានរៀបចំ និងអនុវត្តសាកល្បងនៅតាមក្រុង ស្រុកគោលដៅមួយចំនួន។ សេចក្តីណែនាំទាំងនោះរួមមាន សេចក្តីណែនាំស្តីពីការរៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សា សេចក្តីណែនាំស្តីពីការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាសាធារណៈរបស់ក្រុមប្រឹក្សា និងសេចក្តីណែនាំស្តីពីកិច្ចការរដ្ឋបាល ក្រុង ស្រុក ខណ្ឌ។ សេចក្តីព្រាងសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័នក៏ត្រូវបានពិនិត្យរៀបចំបញ្ចប់ដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅដើមឆ្នាំ២០១២។ សេចក្តីព្រាងស្តីពីការអនុវត្តគម្រោងអភិវឌ្ឍន៍ក្រុង ស្រុក (ផ្នែកដែលមិនពាក់ព័ន្ធកិច្ចលទ្ធកម្ម) ត្រូវបានបញ្ចប់។

**៣.៣.)ការងារអត្រានុកូលដ្ឋាន** ៖បុគ្គលិកផ្នែកបញ្ចូលទិន្នន័យចំនួន៧៥នាក់ (ស្រី២៥នាក់) បុគ្គលិកផ្នែកពិនិត្យផ្ទៀងផ្ទាត់និងកែតម្រូវទិន្នន័យចំនួន៧៥នាក់ (ស្រី១៨នាក់) និងបុគ្គលិកផ្នែកគ្រប់គ្រងចំនួន៣នាក់ត្រូវបានជ្រើសរើស និងចុះកិច្ចសន្យា។ បញ្ជីអត្រានុកូលដ្ឋានចំនួន៩៨៩.១៩៣បញ្ជីត្រូវបានបញ្ចូល និងពិនិត្យផ្ទៀងផ្ទាត់ទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអាត្រានុកូលដ្ឋាន។

**៣.៤.)ការងារគណនេយ្យភាព៖** ការសិក្សាដើម្បីកែសម្រួលយន្តការការងាររបស់ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ត្រូវបានបញ្ចប់ និងដាក់ជូនកិច្ចប្រជុំក្រុមការងារគណនេយ្យភាពថ្នាក់ជាតិពិនិត្យ និងសម្រេច។ ជាមួយគ្នានេះដែរ សេចក្តីព្រាងការកែសម្រួលសេចក្តីណែនាំស្តីពីនីតិវិធីស៊ើបអង្កេត និងដោះស្រាយពាក្យបណ្តឹងរបស់ក្រុមការងារគណនេយ្យភាពរាជធានី ខេត្តក៏ត្រូវបានរៀបចំ និងដាក់ជូនកិច្ចប្រជុំក្រុមការងារគណនេយ្យភាពថ្នាក់ជាតិពិនិត្យ និងសម្រេច។ មន្ត្រីជំនួយការក្រុមគាំទ្រការងារគណនេយ្យភាពរាជធានី ខេត្តចំនួន៤៣នាក់ (ស្រី១០នាក់)ត្រូវបានបណ្តុះបណ្តាល ពង្រឹងសមត្ថភាពពាក់ព័ន្ធនឹងការងារក្រុមគណនេយ្យភាពរាជធានី ខេត្ត។

**៣.៥.) ល័ក្ខខ័ណ្ឌធ្វើការងារ និងសម្ភារៈបរិក្ខារ អាគារសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** ការសិក្សាលទ្ធភាព និងប៉ាន់ស្មានតម្លៃសម្រាប់ការសាងសង់ ជួសជុលអាគារធ្វើការងារក្រុង ស្រុកចំនួន៦២នៅក្នុងខេត្តចំនួន៨ ត្រូវបានចុះសិក្សា និងប្រមូលទិន្នន័យ។

**៣.៦.) ការរៀបចំបង្កើត និងការគាំទ្រការិយាល័យច្រកចេញចូលតែមួយ៖** ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋចាស់ចំនួន៩ត្រូវបានគាំទ្រ និងពង្រឹង។ ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋថ្មីចំនួន៨ត្រូវបានរៀបចំបង្កើត និងដាក់ឱ្យដំណើរការនៅក្នុងក្រុង ស្រុកចំនួន៨។ សេវាចំនួន១៤០ប្រភេទពីក្រសួង ស្ថាប័នចំនួន៨ ត្រូវបានធ្វើប្រតិភូកម្មទៅឱ្យការិយាល័យច្រកចេញចូលតែមួយដើម្បីអនុវត្ត។ ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋទាំង១៧ បានផ្តល់សេវាសរុបចំនួន៦២.៨៨៨សេវា និងទទួលបានចំណូលសរុបចំនួន ៧២៥.៩៧១.៩៥០រៀល។ ការសិក្សាអំពីជម្រើសនៃការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ និងការសិក្សាអំពីជម្រើសនានានៃការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅស្រុកជនបទត្រូវបានរៀបចំ។

**៣.៧.)ការគ្រប់គ្រង សេវារដ្ឋបាល និងការគាំទ្រ៖** មន្ត្រីបម្រើការងារក្រោមក្របខ័ណ្ឌនៃប្រព័ន្ធចំណាយប្រតិបត្តិការអាទិភាពនៃអនុកម្មវិធីទី២នៅថ្នាក់ជាតិចំនួន២៤នាក់ និងនៅថ្នាក់ក្រោមជាតិចំនួន១.០៥៩នាក់ត្រូវបានជ្រើសរើស និងតែងតាំង។ ទីប្រឹក្សាជាតិប្រចាំនៅថ្នាក់ជាតិចំនួន៥នាក់ និងប្រចាំនៅរាជធានី ខេត្តចំនួន៦៧នាក់ត្រូវបានជ្រើសរើស និងចុះកិច្ចសន្យា។

កុំព្យូទ័រចំនួន២៣គ្រឿង ព្រីនទ័រចំនួន៤គ្រឿង ម៉ាស៊ីនស្កេនចំនួន៣គ្រឿង ម៉ាស៊ីនថតចម្លងចំនួន១គ្រឿង ម៉ាស៊ីនថតចំនួន១គ្រឿង ម៉ាស៊ីនបញ្ចាំងLCDចំនួន១គ្រឿង ផ្ទាំងសំពត់សចល័តចំនួន១គ្រឿង និងរថយន្តចំនួន៣គ្រឿង ត្រូវបានធ្វើលទ្ធកម្ម។ ការចំណាយលើការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី២ មានសង្ខេបនៅក្នុងតារាងខាងក្រោម៖

| សមាសភាគ | ថវិកាគ្រោង ($) | ថវិកាចំណាយ($) | % |
|---|---|---|---|
| ការរៀបចំបុគ្គលិក និងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ | 0 | 0 | 0 |
| ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 538.683 | 98.739 | 18,33 |
| ការត្រួតពិនិត្យមើល ការពិនិត្យនីត្យានុកូលភាព ការងារអត្រានុកូលដ្ឋាន និងការងារគណនេយ្យភាព | 521.370 | 184.701 | 35,43 |
| ល័ក្ខខ័ណ្ឌធ្វើការងារ និងសម្ភារៈបរិក្ខារ អាគារសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | 2.456.342 | 1.327.948 | 45,94 |
| ការគ្រប់គ្រង សេវារដ្ឋបាល និងការគាំទ្រ | 2.173.729 | 1.551.471 | 71,37 |
| **សរុប** | **5.690.124** | **3.162.859** | **55,59%** |

## ៤-) សង្ខេបលទ្ធផលការអនុវត្តអនុកម្មវិធីទី៣

ផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី៣ ផ្តោតជាសំខាន់ទៅលើការរៀបចំប្រព័ន្ធគ្រប់គ្រងបុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះរួមមានការរៀបចំនានាសម្រាប់អន្តរកាលនៃការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំក្របខ័ណ្ឌគតិយុត្តអចិន្ត្រៃយ៍សម្រាប់ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ លទ្ធផលសង្ខេបនៃការអនុវត្តផែនការសម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី៣នេះ មានដូចខាងក្រោម៖

**៤.១.)ការរៀបចំសម្រាប់អន្តរកាលនៃការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** បានរៀបចំបញ្ជីសំណួរសម្រាប់ការសិក្សា ពិភាក្សា និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងបានប្រមូលទិន្នន័យសម្រាប់រៀបចំសេចក្តីព្រាងក្របខ័ណ្ឌគតិយុត្តសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ នៅមុនពេល

ដែលមានលក្ខន្តិកៈដោយឡែកសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងបានតាក់តែងបញ្ចប់នូវសេចក្តីព្រាងមាតិកា និងខ្លឹមសារអត្ថបទក្របខ័ណ្ឌគតិយុត្តសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមមាន៖ ការជ្រើសរើសបុគ្គលិករដ្ឋបាលក្រោមជាតិ ការដាក់ឱ្យធ្វើកម្មសិក្សាបុគ្គលិករដ្ឋបាលក្រោមជាតិ ការតាំងស៊ប់ ការដំឡើងថ្នាក់និងឋានន្តរស័ក្តិបុគ្គលិករដ្ឋបាលក្រោមជាតិ និងការតែងតាំងក្នុងមុខដំណែង ។

**៤.២.) ក្របខ័ណ្ឌគតិយុត្តអចិន្ត្រៃយ៍សម្រាប់ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** បានចាប់ផ្តើមរៀបចំសេចក្តីព្រាងខ្លឹមសារគោលសម្រាប់កសាងគោលនយោបាយស្តីពីការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។ សេចក្តីព្រាងនេះនឹងត្រូវដាក់ឱ្យពិភាក្សា ពិគ្រោះយោបល់ជាមួយអនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ ដើម្បីរៀបចំបញ្ចប់នៅក្នុងឆ្នាំ២០១២ ។

ការចំណាយលើការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី៣ មានសង្ខេបនៅក្នុងតារាងខាងក្រោម៖

| សមាសភាគ | ថវិកាគ្រោង ($) | ថវិកាចំណាយ($) | % |
|---|---|---|---|
| ការរៀបចំសម្រាប់អន្តរកាលនៃការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 17.500 | 0 | 0.0 |
| ការរៀបចំក្របខណ្ឌគតិយុត្តអចិន្ត្រៃយ៍សម្រាប់ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 35.000 | 0 | 0.0 |
| ការគ្រប់គ្រងអនុកម្មវិធី | 49.229 | 31.115 | 63,2 |
| សរុប | **101.729** | **31.115** | **31,59** |

**៥-) សង្ខេបលទ្ធផលការអនុវត្តអនុកម្មវិធីទី៤**

ផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី៤ ផ្តោតជាសំខាន់ទៅលើការរៀបចំគោលនយោបាយ និងក្របខ័ណ្ឌច្បាប់សម្រាប់យន្តការហិរញ្ញប្បទានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសថ្នាក់ក្រុង ស្រុក ការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ និងការពង្រឹងស្ថាប័នថ្នាក់ជាតិសម្រាប់ការគាំទ្រ និងត្រួតពិនិត្យ ។ លទ្ធផលសង្ខេបនៃការអនុវត្តផែនការសម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី៤នេះ មានដូចខាងក្រោម ៖

**៥.១.) ការរៀបចំគោលនយោបាយ និងក្របខណ្ឌច្បាប់សម្រាប់យន្តការហិរញ្ញប្បទានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់ ។ សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង

ស្រុក ត្រូវបានរៀបចំ និងដាក់ជូន គ.ជ.អ.ប ពិនិត្យ និងផ្តល់យោបល់មុននឹងដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និងអនុម័ត។ ការសិក្សាដើម្បីផ្តល់ជម្រើសសម្រាប់ការរៀបចំបង្កើតយន្តការផ្តល់ហិរញ្ញប្បទានវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) និងឯកសារទស្សនទានបឋមត្រូវបានរៀបចំ និងពិភាក្សា។ គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តស្តីពីចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ចំណូលពន្ធ និងមិនមែនសារពើពន្ធ) ត្រូវបានសិក្សា។

**៥.២.) ការរៀបចំប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រុង ស្រុក៖** សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុកត្រូវបានរៀបចំ និងដាក់ជូន គ.ជ.អ.ប ដើម្បីពិនិត្យ និងផ្តល់គោលការណ៍ណែនាំ។ សេចក្តីព្រាងប្រកាសណែនាំស្តីពីការរៀបចំ ការអនុម័ត និងអនុវត្តថវិកាក្រុង ស្រុក ត្រូវបានរៀបចំ និងកំពុងត្រូវបានដាក់ឱ្យធ្វើការពិគ្រោះពិភាក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។ ប្រកាស និងសេចក្តីណែនាំចាំបាច់មួយចំនួនផ្សេងទៀតសម្រាប់បម្រើឱ្យការអនុវត្ត និងគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ក៏ត្រូវបានរៀបចំជាសេចក្តីព្រាងបឋមផងដែរ។

**៥.៣.) ការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ៖** ក្នុងផែនការសកម្មភាពឆ្នាំ២០១១ ចំពោះសកម្មភាពពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិនេះ បានផ្តោតទៅលើការបណ្តុះបណ្តាលដល់ថ្នាក់ក្រុង ស្រុកស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក។ អាស្រ័យដោយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុកពុំទាន់ត្រូវបានរៀបចំរួចរាល់ ដូច្នេះសកម្មភាពនេះមិនទាន់ត្រូវបានរៀបចំនៅឡើយ។ ទោះជាយ៉ាងនេះក្តី ក៏ការបណ្តុះបណ្តាលបឋមដល់គណនេយ្យករក្រុង ស្រុក និងឃុំ សង្កាត់ ត្រូវបានរៀបចំជាបណ្តើរដោយអគ្គនាយកដ្ឋានរតនាគារជាតិ។ លើសពីនេះ ទីប្រឹក្សាអភិវឌ្ឍសមត្ថភាពផ្នែកហិរញ្ញវត្ថុចំនួន២៣រូប ក៏ត្រូវបានជ្រើសរើស និងតែងតាំងឱ្យទៅបម្រើការងារនៅតាមរាជធានី ខេត្តទាំងអស់ផងដែរ ដើម្បីគាំទ្រ និងពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តផអ៣។

**៥.៤.) ការពង្រឹងស្ថាប័នថ្នាក់ជាតិសម្រាប់ការគាំទ្រ និងត្រួតពិនិត្យ៖** មន្ត្រីបម្រើការងារក្រោមក្របខ័ណ្ឌនៃប្រព័ន្ធចំណាយអាទិភាពចំនួន០៨រូប និងទីប្រឹក្សាអភិវឌ្ឍសមត្ថភាព០១រូបត្រូវបានជ្រើសរើស និងតែងតាំងឱ្យបម្រើការងារនៅថ្នាក់ជាតិ។ ការសិក្សាវាយតម្លៃលើតម្រូវការអភិវឌ្ឍសមត្ថភាពរបស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋានត្រូវបានរៀបចំ។ ការពង្រឹងសមត្ថភាពដល់មន្ត្រីនៃនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន បានអនុវត្តជាបណ្តើរៗតាមរយៈគម្រោងគាំទ្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ការផ្សព្វផ្សាយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្សព្វផ្សាយអំពីផអ៣នៃកម្មវិធីជាតិក៏ត្រូវបានធ្វើឡើងសម្រាប់បណ្តាអគ្គនាយដ្ឋាន នាយកដ្ឋានទាំងអស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ។

ការចំណាយលើការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី៤ មានសង្ខេបនៅក្នុងតារាងខាងក្រោម៖

| សមាសភាគ | ថវិកាគ្រោង ($) | ថវិកាចំណាយ($) | % |
|---|---|---|---|
| ការរៀបចំគោលនយោបាយ និងក្របខណ្ឌច្បាប់សម្រាប់យន្តការហិរញ្ញប្បទានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 109.250 | 0 | 0,0 |
| ការរៀបចំប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រុង ស្រុក | 90.000 | 0 | 0,0 |
| ការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ | 165.448 | 46 | 0,0 |
| ការពង្រឹងស្ថាប័នថ្នាក់ជាតិសម្រាប់ការគាំទ្រ និងត្រួតពិនិត្យ | 107.570 | 38.640 | 35,9 |
| ការគ្រប់គ្រងអនុកម្មវិធី | 729.255 | 412.866 | 56,6 |
| **សរុប** | **1.201.523** | **451.552** | **37,58** |

**៦-) សង្ខេបលទ្ធផលការអនុវត្តអនុកម្មវិធីទី៥**

ផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី៥ ផ្តោតជាសំខាន់ទៅលើការរៀបចំបង្កើតប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការអភិវឌ្ឍសមត្ថភាពកសាងផែនការព្រមទាំងការកសាងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ លទ្ធផលសង្ខេបនៃការអនុវត្តផែនការសម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី៥នេះ មានដូចខាងក្រោម ៖

**៦.១.) ការរៀបចំបង្កើតប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំដោយផ្អែកលើមូលដ្ឋាននៃប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលបានអនុម័តនៅចុងឆ្នាំ២០១០។ ក្រៅពីសេចក្តីណែនាំបច្ចេកទេសនេះ សេចក្តីណែនាំចាំបាច់មួយចំនួនផ្សេងទៀតសម្រាប់ការពង្រឹង និងកែលំអកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក៏ត្រូវបានរៀបចំ និងកែសម្រួល ដើម្បីផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីពាក់ព័ន្ធនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ សេចក្តីណែនាំទាំងនោះរួមមាន សេចក្តីណែនាំស្តីពីការកែច្នៃ និងប្រើប្រាស់ទិន្នន័យមូលដ្ឋានឃុំ សង្កាត់ (CDB) និងតារាងពិន្ទុគោលដៅអភិវឌ្ឍន៍សហស្សវត្សរកម្ពុជា (Score Card CMDGs) សៀវភៅណែនាំស្តីពីកម្រងសំណួរទិន្នន័យភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងកម្មវិធីទិន្នន័យមូលដ្ឋានឃុំ សង្កាត់។

**៦.២.) ការអភិវឌ្ឍសមត្ថភាពសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ និងការកសាងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** ក្នុងឆ្នាំ២០១១នេះ មានវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើនពាក់ព័ន្ធនឹងប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឡើង ដែលក្នុងនោះរួមមាន៖

- វគ្គបណ្តុះបណ្តាលគ្រូបង្គោលរាជធានី ខេត្ត រយៈពេល៥ថ្ងៃ មានសិក្ខាកាមចូលរួមចំនួនសរុប១៥២រូប
- សិក្ខាសាលាផ្សព្វផ្សាយដល់មន្ត្រីរដ្ឋបាលជាន់ខ្ពស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានប្រធានក្រុមប្រឹក្សាអភិបាលរាជធានី ខេត្ត និងមន្ត្រីជាន់ខ្ពស់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានចំនួនសរុបប្រមាណ១០៧រូប
- សិក្ខាសាលាផ្សព្វផ្សាយដល់ថ្នាក់ដឹកនាំរាជធានី ខេត្ត រួមមាន អភិបាលរង និងសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ដែលមានចំនួនសរុប១០៣៤រូប
- វគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់រាជធានី ខេត្តដែលមានសិក្ខាកាមសរុបមានចំនួន៥៥២រូប សម្រាប់ធ្វើការបណ្តុះបណ្តាលបន្តដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- វគ្គបណ្តុះបណ្តាលក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ដែលមានចំនួនសរុប១៣២៩រូប
- សិក្ខាសាលាផ្សព្វផ្សាយដល់ថ្នាក់ដឹកនាំក្រុង ស្រុក ខណ្ឌ ដែលជាប្រធានក្រុមប្រឹក្សា និងអភិបាលក្រុង ស្រុក ខណ្ឌ ដែលមានចំនួនសរុប៣៨៦រូប
- វគ្គបណ្តុះបណ្តាលក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ
- វគ្គបណ្តុះបណ្តាលស្តីពីការវិភាគ និងប្រើប្រាស់ព័ត៌មានសម្រាប់រៀបចំផែនការថ្នាក់ក្រោមជាតិដែលមានអ្នកចូលរួមសរុបចំនួន១៤១នាក់ (ស្ត្រី២០នាក់) មកពីមន្ទីរផែនការខេត្ត និងទីចាត់ការផែនការ និងវិនិយោគសាលា រាជធានី សាលាខេត្ត
- វគ្គបណ្តុះបណ្តាលស្តីពីការកែច្នៃ និងប្រើប្រាស់ទិន្នន័យទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងតារាងពិន្ទុគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ដែលមានអ្នកចូលរួមចំនួន៩៥នាក់ (ស្ត្រី១៨នាក់) មកពីមន្ទីរផែនការខេត្ត និងទីចាត់ការផែនការ និងវិនិយោគសាលារាជធានី សាលាខេត្ត
- វគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់កម្រងសំណួរនេះ និងការប្រមូលទិន្នន័យមូលដ្ឋានដែលមានអ្នកចូលរួមចំនួន១៨៥នាក់ (ស្ត្រី៣៥នាក់) មកពីមន្ទីរផែនការខេត្ត និងទីចាត់ការផែនការ និងវិនិយោគសាលារាជធានី សាលាខេត្ត តំណាងអង្គការយូនីសេហ្វ
- វគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់កម្មវិធីទិន្នន័យមូលដ្ឋានដែលបានកែសម្រួល ដែលមានអ្នកចូលរួមចំនួន១១០នាក់ (ស្ត្រី១៣នាក់) មកពីមន្ទីរផែនការខេត្ត និងតំណាងអង្គការយូនីសេហ្វ។

ការចំណាយលើការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី៥ មានសង្ខេបនៅក្នុងតារាងខាងក្រោមៈ

| សមាសភាគ | ថវិកាគ្រោង($) | ថវិកាចំណាយ($) | % |
|---|---|---|---|
| ការរៀបចំបង្កើតប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 77.236 | 59.354 | 76,8 |
| ការអភិវឌ្ឍសមត្ថភាពកសាងផែនការ និងការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | 249.314 | 78.146 | 31,3 |
| ការគ្រប់គ្រងអនុកម្មវិធី | 324.827 | 63.848 | 19,7 |
| **សរុប** | **651.377** | **201.348** | **30,91** |

**៧) សង្ខេបលទ្ធផលការអនុវត្តអនុកម្មវិធីទី៦**

ផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី៦ ផ្តោតជាសំខាន់ទៅលើការសិក្សាជម្រើសនានាសម្រាប់ការអភិវឌ្ឍន៍សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ លទ្ធផលសំខាន់នៃការអនុវត្តក្នុងឆ្នាំ២០១១ គឺការសិក្សាស្វែងយល់អំពីជម្រើស និងពិនិត្យអំពីទម្រង់នៃការបង្កើតរចនាសម្ព័ន្ធ និងរបៀបដឹកនាំសមាគមអាជ្ញាធរមូលដ្ឋានតាមរយៈការសិក្សាស្រាវជ្រាវលើឯកសារនៃបណ្តាប្រទេសនានា ដូចជាប្រទេសហ្វីលីពីន ប៉ូលីវី កាណាដា វៀតណាម និងប្រទេសឥណ្ឌូនេស៊ី។ ផ្អែកលើលទ្ធផលនៃការសិក្សាស្វែងយល់នេះ អគ្គលេខាធិការដ្ឋានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់បានរៀបចំបង្កើតជម្រើសស្តីពីការបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ដាក់ជូនពិភាក្សាជំហានបឋម និងសុំគោលការណ៍ឯកភាពពីរាជរដ្ឋាភិបាលក្នុងសន្និបាតបូកសរុបសមិទ្ធិផលការងារក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២ ដែលបានរៀបចំឡើងនាថ្ងៃទី១៧-១៨ ខែសីហា ឆ្នាំ២០១១។ ក្រៅពីការរៀបចំបង្កើតជម្រើសនេះ អគ្គលេខាធិការដ្ឋាននៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ក៏បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយទស្សនទាន និងការអង្កេតជំហានដំបូងលើទម្រង់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា ដែលក្នុងពេលនោះ តំណាងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ បានគាំទ្រលើសលប់ក្នុងការបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ២ប្រភេទគឺៈ សមាគមក្រុមប្រឹក្សាថ្នាក់តំបន់ដែលមានក្រុមប្រឹក្សា រាជធានី ខេត្ត និងសមាគមក្រុមប្រឹក្សាមូលដ្ឋានដែលមានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ហើយសមាគមទាំង២នេះត្រូវមានយន្តការទំនាក់ទំនងគ្នា។ កិច្ចប្រជុំនេះ មានសិក្ខាកាមចូលរួមប្រមាណ៦00នាក់ គឺជាតំណាងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិមកពីរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ទូទាំងប្រទេស។

ការចំណាយលើការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១១នៃអនុកម្មវិធីទី៦ មានសង្ខេបនៅក្នុងតារាងខាងក្រោមៈ

| សមាសភាគ | ថវិកាគ្រោង ($) | ថវិកាចំណាយ ($) | % |
|---|---|---|---|
| ការបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | 75.000 | 10.977 | 14,6 |
| ការគ្រប់គ្រងអនុកម្មវិធី | 400.313 | 77.039 | 4,9 |
| **សរុប** | **475.313** | **88.016** | **18,52** |

### ៨-) ការគាំទ្រឃុំ សង្កាត់

ការគាំទ្រដល់ឃុំ សង្កាត់គឺជាកិច្ចការដ៏ចាំបាច់មួយដែលបានកំណត់នៅក្នុងផអ៣ ក៏ដូចជាក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១១។ ក្នុងឆ្នាំ២០១១ ទោះបីមានការជួបប្រទះនូវគ្រោះទឹកជំនន់យ៉ាងធ្ងន់ធ្ងរលើឃុំ សង្កាត់មួយចំនួនធំក្តី ក៏ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១០ និងឆ្នាំ២០១១ទទួលលទ្ធផលគួរឱ្យកត់សម្គាល់។ កិច្ចសន្យាឃុំ សង្កាត់ឆ្នាំ២០១០សរុបមានចំនួន១.៦៧៩កិច្ចសន្យា ក្នុងនោះ៩៣%បានអនុវត្តចប់ ១០០% និង ០៧%ទៀតកំពុងដំណើរការ។ គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១១សរុបមានចំនួន១.៨៨០គម្រោង ក្នុងនោះ៨០%កំពុងត្រូវបានអនុវត្ត ១០%បានបញ្ចប់ការដេញថ្លៃ និង១០%កំពុងធ្វើការសិក្សាលទ្ធភាពគម្រោង ។ ជាមួយគ្នានេះដែរ មកដល់ពេលនេះ មូលនិធិឃុំសង្កាត់ឆ្នាំ២០១១ ចំនួន១៥៩.៣៩៨ លានរៀល ឬស្មើនឹង១០០%នៃមូលនិធិឃុំសង្កាត់ឆ្នាំ២០១១សរុប ត្រូវបានរៀបចំអាណត្តិផ្ទេរចូលទៅក្នុងមូលនិធិឃុំ សង្កាត់។

## គ-) អំពីការកៀរគរធនធាន និងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍

ក្នុងឆ្នាំ២០១១នេះ គ.ជ.អ.ប បានសម្របសម្រួល សហការការងារយ៉ាងជិតស្និទ្ធ និងពិភាក្សាច្រើនលើកច្រើនសារជាមួយដៃគូអភិវឌ្ឍន៍សំខាន់ៗ ដើម្បីធានាដល់ការបន្តការគាំទ្រមកលើកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមល័ក្ខខ័ណ្ឌនៃការពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ព្រមទាំងការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការប្រើប្រាស់ជំនួយគាំទ្រទាំងនេះ។ តាមរយៈការខិតខំប្រឹងប្រែងនេះ ជារួមដៃគូអភិវឌ្ឍន៍សំខាន់ៗទាំងអស់បានឯកភាពគ្នា ក្នុងការគាំទ្រដល់កម្មវិធីជាតិរយៈពេល១០ឆ្នាំ និងការអនុវត្តផអ៣ ក្រោមក្របខ័ណ្ឌនៃ"វិធីសាស្ត្រផ្អែកតាមកម្មវិធី" ក្នុងគោលបំណងពង្រឹងភាពជាម្ចាស់និងការប្រើប្រាស់នូវប្រព័ន្ធនានារបស់រាជរដ្ឋាភិបាល ព្រមទាំងធ្វើសុខដុមនីយកម្ម និងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយគាំទ្ររបស់ដៃគូអភិវឌ្ឍន៍។ ក្នុងខែឧសភា ឆ្នាំ២០១១កន្លងទៅនេះ អនុស្សរណៈស្តីពីវិធីសាស្ត្រផ្អែកតាមកម្មវិធីរវាង គ.ជ.អ.ប ជាមួយនឹងដៃគូអភិវឌ្ឍន៍សំខាន់ៗចំនួនបួន គឺ ស៊ុយអែត (ស៊ីដា) ដាណឺម៉ាក់ (ដានីដា) មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF) និងធនាគារអភិវឌ្ឍអាស៊ី (ADB)ត្រូវបានចុះហត្ថលេខា។ ដោយឡែកនៅចុងឆ្នាំ២០១១នេះ ស៊ីដា បានរៀបចំឱ្យមានការវាយតម្លៃអំពីការគ្រប់គ្រងរបស់

លេខាធិការដ្ឋាន គ.ជ.អ.ប ដែលការវាយតម្លៃនេះ ត្រូវបានអនុវត្តដោយក្រុមហ៊ុន Price Waterhouse ។ ផ្អែកតាមលទ្ធផលជាវិជ្ជមាននៅក្នុងរបាយការណ៍វាយតម្លៃរបស់ក្រុមហ៊ុននេះ ដែលត្រូវបានចែកផ្សាយដល់ដៃគូអភិវឌ្ឍន៍នានា បានជំរុញឱ្យមានការបង្កើនការតាំងចិត្តជួយគាំទ្រពីដៃគូអភិវឌ្ឍន៍នានា ចំពោះកិច្ចដំណើរការកំណែទម្រង់នេះជាបន្តទៅទៀត ។

ជារួម ដៃគូអភិវឌ្ឍន៍សំខាន់ៗមួយចំនួនបានបង្ហាញឱ្យឃើញនូវការសម្រេចចិត្ត និងជំហរនៃការគាំទ្ររបស់ខ្លួនដូចខាងក្រោម ៖

- **ស៊ុយអែត (ស៊ីដា)** ៖ គឺជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់មួយដែលបានជួយគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការអស់រយៈពេលជាច្រើនឆ្នាំកន្លងមកតាមរយៈគម្រោងនានារបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ។ ក្រោមក្របខ័ណ្ឌនៃរបត់ថ្មីនេះ ស៊ុយអែតបានធ្វើការសម្រេចចិត្តបន្តផ្តល់ការគាំទ្រហិរញ្ញប្បទានដល់កម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដោយផ្ទាល់ដល់រាជរដ្ឋាភិបាលកម្ពុជានូវមូលនិធិចំនួនប្រមាណ**២៨លានដុល្លារ** តាមរយៈកិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទាន ដែលបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយរដ្ឋាភិបាលស៊ុយ អែត នាខែឧសភា ឆ្នាំ២០១១។ ហិរញ្ញប្បទានគាំទ្រនេះត្រូវបានកំណត់ឱ្យប្រើប្រាស់ក្នុងរយៈពេល១៩ខែ គឺពីខែមេសា ឆ្នាំ២០១១ដល់ខែកញ្ញាឆ្នាំ ២០១២ សម្រាប់ការគាំទ្រប្រតិបត្តិការ និងការវិនិយោគតាមរយៈមូលនិធិក្រុង ស្រុក ។
- **ដាណឺម៉ាក់ (ដានីដា)** ៖ ក៏ជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់មួយដែលបានជួយគាំទ្រដោយផ្តោតជាសំខាន់ទៅលើការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ និងលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ តាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ដាណឺម៉ាក់ បានសម្រេចចិត្តបន្តការគាំទ្ររបស់ខ្លួនដល់កម្មវិធីជាតិ និងការអនុវត្តផអពនូវមូលនិធិសរុបចំនួន១,៩លានដុល្លារ សម្រាប់ប្រើប្រាស់នៅក្នុងឆ្នាំ២០១១នេះ ។
- **កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)** ៖ គឺជាដៃគូអភិវឌ្ឍន៍ដែលធ្លាប់បានសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដើម្បីផ្តល់ការគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា។ ក្នុងឆ្នាំ២០១១នេះ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បានឯកភាពឱ្យប្រើប្រាស់មូលនិធិដែលនៅសេសសល់ចំនួន**១,៦លានដុល្លារ** ពីគម្រោងគាំទ្រការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD) របស់ខ្លួនសម្រាប់ប្រើប្រាស់នៅក្នុងត្រីមាសទី១ដើមឆ្នាំ២០១១។ សម្រាប់ឆ្នាំ២០១២ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ មានគម្រោងផ្តល់ការគាំទ្រប្រមាណ ៨០០.០០០ដុល្លារ ដែលក្នុងនោះមានគម្រោងគាំទ្រសម្ព័ន្ធភាពជាតិ ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រមាណ

៤០០.០០០ដុល្លារ និងគាំទ្រគម្រោងសាកល្បងពង្រឹងប្រព័ន្ធកសាង ផែនការអភិវឌ្ឍន៍ខេត្តគោលដៅមួយ ប្រមាណ៤០០.០០០ដុល្លារ។

- **មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF)** ៖ ជាដៃគូអភិវឌ្ឍន៍ដែលផ្តល់ការគាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដោយផ្តោតជាសំខាន់ទៅលើពង្រឹងយន្តការដោះស្រាយបញ្ហាសង្គមនៅថ្នាក់មូលដ្ឋាន ជាពិសេសថ្នាក់ឃុំសង្កាត់ តាមរយៈកម្មវិធីសិទ្ធិកុមាររបស់ខ្លួន។ ក្រោមក្របខ័ណ្ឌនៃរបត់ថ្មីនេះ មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ នឹងរក្សាការគាំទ្រតាមរយៈកម្មវិធីសិទ្ធិកុមារ ក្នុងបែបផែនជាគម្រោងដោយឡែក តែត្រូវអនុវត្តដោយផ្អែកលើល័ក្ខខ័ណ្ឌនៃវិធីសាស្ត្រផ្អែកតាមកម្មវិធី។ មូលនិធិសរុបរបស់កម្មវិធីនេះមានចំនួនប្រមាណ**១លានដុល្លារ** សម្រាប់ឆ្នាំ២០១១នេះ។ មូលនិធិនេះមួយផ្នែកបានត្រូវផ្ទេរឱ្យទៅឃុំ សង្កាត់សម្រាប់គាំទ្រដល់សកម្មភាព និងប្រតិបត្តិការរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និង កុមារឃុំ សង្កាត់។
- **សហភាពអឺរ៉ុប (EU)** ៖ ផ្អែកលើលទ្ធផលនៃការវាយតម្លៃរួមគ្នាដោយដៃគូអភិវឌ្ឍន៍លើឯកសារ ផអព សហភាពអឺរ៉ុបបានបង្ហាញពីឆន្ទៈ ក្នុងការគាំទ្រ និងផ្តល់ហិរញ្ញប្បទានដល់ការអនុវត្តផអពនៃកម្មវិធីជាតិនូវមូលនិធិចំនួនប្រមាណ**១២-១៥លានដុល្លារ** សម្រាប់រយៈពេលបីឆ្នាំ។ ដោយសារនីតិវិធីសម្រាប់ការរៀបចំ និងអនុម័តមូលនិធិជំនួយរបស់សហភាពអឺរ៉ុបត្រូវការពេលវេលាយូរ ហេតុនេះចំពោះការចាប់ផ្តើមគាំទ្រក្នុងដំណាក់កាលថ្មីនេះ សហភាពអឺរ៉ុបបានសម្រេចចិត្តផ្តល់ការគាំទ្រ ក្នុងឆ្នាំ២០១២ តាមរយៈគម្រោង EU–SPACE ដែលមានស្រាប់របស់ខ្លួន ដោយបន្ថែមមូលនិធិប្រមាណចំនួន**១លានដុល្លារ** និងពន្យារពេលអនុវត្តគម្រោងនេះទៅដល់ពាក់កណ្តាលឆ្នាំ២០១២។ ការគាំទ្រថ្មីរបស់សហភាពអឺរ៉ុប ក្នុងរបត់ថ្មីនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នឹងចាប់ផ្តើមពីពាក់កណ្តាលឆ្នាំ២០១២ទៅ។
- **ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)** ៖ ជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់មួយក្នុងចំណោមដៃគូអភិវឌ្ឍន៍សំខាន់ៗផ្សេងទៀត ក្នុងការគាំទ្រកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា។ ការគាំទ្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងរយៈពេលកន្លងមក បានធ្វើឡើងតាមបែបផែនជាគម្រោងដោយឡែកៗ ដែលក្នុងនោះរួមមានគម្រោងអភិវឌ្ឍក្រុមប្រឹក្សាឃុំ សង្កាត់ដំណាក់កាលទី១ និងដំណាក់កាលទី២ (CCDP និង CCDP-II) ដែលផ្តោតជាសំខាន់ទៅលើការសាងសង់អាគារការិយាល័យឃុំ សង្កាត់ ការអភិវឌ្ឍន៍សមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ និងការចុះបញ្ជីអត្រានុកូលដ្ឋាន គម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប (TSSLP) ដែលផ្តោតជាសំខាន់ទៅលើការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរស់នៅជុំវិញបឹងទន្លេសាប តាមរយៈប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការឃុំ សង្កាត់ និងគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចបឹងទន្លេសាប។ ក្រៅពីនេះ

ធនាគារអភិវឌ្ឍន៍អាស៊ីបាន និងកំពុងអនុវត្តគម្រោងផ្តល់ជំនួយបច្ចេកទេសមួយសម្រាប់គាំទ្រកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលផ្តោតជាសំខាន់ទៅលើការសិក្សាអំពីជម្រើសនានាសម្រាប់ការប្រគល់ និងផ្ទេរមុខងារ និងធនធានឱ្យទៅរដ្ឋបាល ថ្នាក់ក្រោមជាតិ និងការរៀបចំប្រព័ន្ធវិមជ្ឈការហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងដំណាក់កាលថ្មីនេះ ធនាគារអភិវឌ្ឍន៍អាស៊ី បានបង្ហាញនូវឆន្ទៈខ្ពស់ក្នុងការបន្តការគាំទ្ររបស់ខ្លួនមកលើកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយបានកំណត់ការសម្រេចចិត្តនៃការគាំទ្រនេះនៅក្នុងយុទ្ធសាស្ត្រនៃភាពជាដៃគូសម្រាប់ប្រទេសកម្ពុជារយៈពេលបីឆ្នាំ គឺពីឆ្នាំ២០១១-២០១៣របស់ខ្លួន។ ផ្អែកតាមយុទ្ធសាស្ត្រនៃភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ីគ្រោងនឹងផ្តល់ការគាំទ្រសរុបចំនួនប្រមាណ**៥៥,៣៦លានដុល្លារ**សម្រាប់ពីរដំណាក់កាលផ្សេងគ្នា។ ដំណាក់កាលទី១ មានឥណទានសរុបចំនួនប្រមាណ**៣០,៣៦លានដុល្លារ** ដែលនឹងត្រូវចាប់ផ្តើមអនុវត្តពីចុងឆ្នាំ២០១២ ដល់ឆ្នាំ២០១៤។ ដំណាក់កាលទី២នឹងមានឥណទានសរុបចំនួនប្រមាណ**២៥លានដុល្លារ** ដែលនឹងត្រូវចាប់ផ្តើមអនុវត្តពីឆ្នាំ២០១៤តទៅ។ បច្ចុប្បន្ននេះ ធនាគារអភិវឌ្ឍន៍អាស៊ី បាន និងកំពុងចាប់ផ្តើមសិក្សា និងពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធនានាលើលទ្ធភាពនៃការរៀបចំគម្រោងផ្តល់ហិរញ្ញប្បទានឥណទានក្នុងដំណាក់កាលទី១របស់ខ្លួននេះ ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

- **ធនាគារពិភពលោក (World Bank)** ៖ គឺជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់មួយ ដែលបានផ្តល់ការគាំ ទ្រដល់កិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមរយៈគម្រោង វិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋានដំណាក់កាលទី១ និងទី២ ដែលមានមូលនិធិសរុប ប្រមាណ៦០លានដុល្លារ ចាប់អនុវត្តពីឆ្នាំ២០០៣ និងបានបញ្ចប់នៅចុងឆ្នាំ២០១០។ ទោះបីការ គាំទ្ររបស់ធនាគារ ពិភពលោកមានទម្រង់ជាគម្រោងដោយឡែកក៏ដោយ ក៏គម្រោងនេះបានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងមូលនិធិឃុំសង្កាត់របស់រាជរដ្ឋាភិបាលសម្រាប់ការគាំទ្ររបស់ខ្លួន។ ក្រៅពីនេះ ធនាគារពិភពលោកក៏មានគម្រោង២ផ្សេងទៀត ដែលកំពុងអនុវត្តដោយមានកិច្ចសហការជាមួយ គ.ជ.អ.ប គឺគម្រោងពង្រឹងអភិបាលកិច្ចមូលដ្ឋាន (DFGG) ដោយផ្តោតការគាំទ្រដល់ការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងគម្រោងបែងចែកដីធ្លីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម (LASED)។ ក្នុងដំណាក់កាលថ្មីនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទោះបីជាមានការពិភាក្សា និងឯកភាពកម្រិតបច្ចេកទេសជាច្រើនលើកច្រើនសារយ៉ាងណាក៏ដោយ ក៏ធនាគារពិភពលោកមិនបានបង្ហាញជំហរច្បាស់លាស់ណាមួយក្នុងការសម្រេចចិត្តចំពោះការគាំទ្រជាថ្មីរបស់ខ្លួននៅឡើយ។
- **រដ្ឋាភិបាលជប៉ុនក្រោមក្របខ័ណ្ឌនៃគម្រោងអភិវឌ្ឍន៍សមត្ថភាពសម្រាប់អនុវត្តច្បាប់រៀបចំអង្គការនៅថ្នាក់រាជធានី ខេត្ត (PILAC 2)** ៖ ជាការគាំទ្រក្នុងបែបផែនជាគម្រោងដោយឡែករបស់រដ្ឋាភិបាល

ជប៉ុន តាមរយៈអង្គការ Jica លើកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលផ្តោតជាសំខាន់ទៅលើប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។ គម្រោងនេះ នឹងបន្តគាំទ្ររបស់ដល់ឆ្នាំ២០១៥។

- **កម្មវិធីជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលី** (AusAID)៖ ជាដៃគូអភិវឌ្ឍន៍ថ្មីមួយដែលកំពុងផ្តល់ការចាប់អារម្មណ៍ក្នុងការគាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ នៅក្នុងឆ្នាំ២០១២ ខាងមុខនេះ កម្មវិធីជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលីដោយសហការជាមួយនឹងមូលនិធិអភិវឌ្ឍអង្គការសហប្រជាជាតិ (UNCDF) មានបំណងផ្តល់ការគាំទ្រដល់ គ.ជ.អ.ប ក្នុងការរៀបចំកម្មវិធីមួយសម្រាប់គាំទ្រដល់ការរៀបចំ និងអនុវត្តសាកល្បងនូវការផ្ទេរមុខងារ និងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសឱ្យទៅស្រុក ឃុំគោលដៅមួយចំនួន ដែលផ្តោតជាសំខាន់ទៅលើមុខងារពាក់ព័ន្ធជាមួយនឹង វិស័យសុខាភិបាល អប់រំ និងកសិកម្ម។ ពាក់ព័ន្ធនឹងកម្មវិធីសាកល្បងនេះ កម្មវិធីជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលី នឹងគ្រោងគាំទ្រហិរញ្ញប្បទានចំនួនប្រមាណ **៣00.000ដុល្លារ**សម្រាប់ឆ្នាំ២០១២ និងមានហិរញ្ញប្បទានប្រមាណ២០លានដុល្លារ សម្រាប់ផ្តល់ការគាំទ្រពីឆ្នាំ២០១៣ និង២០១៤ក្នុងករណីដែលកម្មវិធីសាកល្បងដែលត្រូវអនុវត្តក្នុងឆ្នាំ២០១២ ទទួលបានជោគជ័យ។
- **មូលនិធិអភិវឌ្ឍអង្គការសហប្រជាជាតិ** (UNCDF)៖ ជាដៃគូអភិវឌ្ឍន៍មួយដែលផ្តោតការគាំទ្រលើការរៀបចំប្រព័ន្ធកសាងផែនការ និងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងឆ្នាំ២០១២ មូលនិធិអភិវឌ្ឍអង្គការសហប្រជាជាតិ នឹងបន្តការគាំទ្រដល់ការសិក្សាកែសម្រួលប្រព័ន្ធ ដំណើរការកសាងផែនការ និងការងារពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ដែលមានមូលនិធិសរុបចំនួនប្រមាណ៣00.000 ដុល្លារ។

# III. បញ្ហាប្រឈមជាគន្លឹះ និងដំណោះស្រាយ

ទោះបីបានឆ្លងផុតយ៉ាងជោគជ័យនូវដំណាក់កាលអន្តរកាលដ៏លំបាកស្មុគស្មាញ នាចុងឆ្នាំ២០១០ និងឆ្នាំ ២០១១នេះក៏ដោយ ក៏ជោគជ័យនេះបានដើរទន្ទឹមជាមួយនឹងបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលត្រូវបន្តយកចិត្តទុកដាក់ដោះស្រាយនៅក្នុងឆ្នាំ២០១២។ បញ្ហាប្រឈមជាគន្លឹះទាំងនោះរួមមាន ៖

## ក-) ស្ថាប័ន និងប្រព័ន្ធគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងការអនុវត្តរយៈពេលជាង២ឆ្នាំកន្លងមកនេះ ទោះបីជាលិខិតបទដ្ឋានគតិយុត្តជាច្រើនពាក់ព័ន្ធនឹងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងការប្រព្រឹត្តទៅរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ក៏ពិតមែន ក៏លិខិតបទដ្ឋានទាំងនោះមិនទាន់បានឆ្លើយតបទាំងស្រុងទៅនឹងលក្ខខណ្ឌគោលនយោបាយសម្រាប់ការពង្រឹងស្ថាប័ន និងគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដូចដែលបានកំណត់នៅក្នុងច្បាប់រៀបចំអង្គការនៅឡើយ។ ការពុំទាន់បានដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងការខ្វះខាតនូវនីតិវិធីរដ្ឋបាលសម្រាប់ការប្រព្រឹត្តទៅផ្នែកស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចបណ្តាលឱ្យមានផលប៉ះពាល់ដល់ការពង្រឹងខ្សែគណនេយ្យភាព រវាងអង្គរដ្ឋបាលជាមួយនឹងក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល។ ទោះបីជាផែនការសកម្មភាព និងថវិកាឆ្នាំ២០១១បានគ្រោងឱ្យមានការរៀបចំបង្កើតលិខិតបទដ្ឋានគតិយុត្តចាំបាច់ទាំងនេះ ដើម្បីដោះស្រាយបាននូវបញ្ហាខាងលើក្តី ក៏ការរៀបចំលិខិតបទដ្ឋានទាំងនោះភាគច្រើនកំពុងស្ថិតនៅក្នុងដំណាក់កាលនៃការសិក្សា និងការរៀបចំជាសេចក្តីព្រាង។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ក្នុងឆ្នាំ២០១២ ត្រូវជំរុញដល់ការរៀបចំបញ្ចប់ និងដាក់ឱ្យប្រើប្រាស់នូវគោលនយោបាយស្តីពីការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ លិខិតបទដ្ឋានសម្រាប់គ្រប់គ្រងបុគ្គលិកដែលបានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងដំណាក់កាលអន្តរកាល និងលក្ខន្តិកៈដោយឡែកសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ លើសពីនេះ ត្រូវបន្តយកចិត្តទុកដាក់លើការរៀបចំ និងកែសម្រួលគោលការណ៍ណែនាំស្តីពីនីតិវិធីរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសសម្រាប់ថ្នាក់ក្រុង ស្រុក។

## ខ-) ប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ការរៀបចំផែនការអភិវឌ្ឍន៍ក្នុងន័យឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន គឺជាតម្រូវការដ៏ចាំបាច់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ នៅក្នុងឆ្នាំ២០១១នេះ ទោះបីបានរៀបចំបង្កើត និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្តី ក៏ការអនុវត្តជាក់ស្តែងនៃការរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌភាគច្រើន មិនបានបញ្ចប់តាមកាលកំណត់ និងបំពេញ

បានតាមលក្ខខណ្ឌនៃការរៀបចំផែនការអភិវឌ្ឍន៍ទាំងស្រុងនៅឡើយ។ បញ្ហាទាំងនេះ កើតឡើងបណ្តាលមកពីកិច្ចការនេះជាការងារថ្មី រយៈពេលសម្រាប់ការរៀបចំខ្លីពេក នីតិវិធីស្មុគស្មាញ និងការមិនមានព័ត៌មានច្បាស់លាស់អំពីប្រភពថវិកាសម្រាប់ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដែលជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍របស់រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និងជាពិសេសមិនមានព័ត៌មានអំពីធនធានថវិកា ដែលខ្លួនអាចមានសម្រាប់រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន។ ការយឺតយ៉ាវនៃការរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងការគ្មានប្រភពថវិការបស់ខ្លួន បានផ្តល់ផលប៉ះពាល់ដល់ការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលទាំងនោះ ទាំងនៅក្នុងឆ្នាំ២០១១ និងឆ្នាំ២០១២ផងដែរ។ លើសពីនេះ ប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានដាក់ឱ្យប្រើប្រាស់កន្លងមកនេះ ក៏មិនទាន់មានលក្ខណៈឆ្លើយតប និងភាពសមស្របទៅតាមចរិកលក្ខណៈផ្សេងៗនៃប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗឡើយ។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ នៅឆ្នាំ២០១២ ត្រូវផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតក្នុងការពិនិត្យមើលឡើងវិញនូវប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការកំណត់ប្រតិទិនសម្រាប់ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលសម្រាប់ឆ្នាំ ២០១៣-២០១៥ ឱ្យបានច្បាស់លាស់ ដែលឆ្លុះបញ្ចាំងទៅនឹងស្ថានភាព និងពេលវេលាជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវធ្វើឱ្យមានការបន្សុីគ្នារវាងនីតិវិធីរៀបចំផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

**គ-) ការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងធនធានហិរញ្ញវត្ថុក្រុង ស្រុក**

ក្នុងការរៀបចំឱ្យថ្នាក់ក្រុង ស្រុកមានប្រភពធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារជាជម្រើស ដើម្បីបម្រើឱ្យកិច្ចអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនផ្អែកតាមផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគដែលបានរៀបចំរួចហើយ ព្រមទាំងការរៀបចំគ្រប់គ្រងធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធិភាព តម្លាភាព និងគណនេយ្យភាពតាមការកំណត់របស់ច្បាប់រៀបចំអង្គការ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺតម្រូវឱ្យមានការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តជាច្រើន ដូចជាអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ប្រកាសស្តីពីទម្រង់ និងមាតិកាថវិកាក្រុង ស្រុក ប្រកាសស្តីពីមាតិកាគណនីនៃគណនេយ្យថវិកាក្រុង ស្រុក សេចក្តីណែនាំស្តីពីការរៀបចំ ការអនុម័ត និងការអនុវត្តថវិកាក្រុង ស្រុក សេចក្តីណែនាំស្តីពីការគ្រប់គ្រងសាច់ប្រាក់ និងប្រព័ន្ធទូទាត់ថវិកាក្រុង ស្រុក និងសេចក្តីណែនាំស្តីពីប្រព័ន្ធគណនេយ្យភាពហិរញ្ញវត្ថុក្រុង ស្រុក ព្រមទាំងសេចក្តីណែនាំពាក់ព័ន្ធនានាផ្សេងទៀត។

ការយឺតយ៉ាវនៃការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តទាំងនេះនឹងមិនត្រឹមតែផ្តល់ផលប៉ះពាល់ដល់ការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ក្រុង ស្រុកនៅក្នុងឆ្នាំ២០១១នោះឡើយ ប៉ុន្តែក៏នឹងធ្វើឱ្យមានការប៉ះពាល់ដល់ដំណើរការកំណែទម្រង់នៅក្នុងឆ្នាំ២០១២ និង២០១៣ផងដែរ។ ភាពយឺតយ៉ាវ

នានាក្នុងការដាក់ឱ្យអនុវត្តមូលនិធិក្រុង ស្រុក ក៏ប៉ះពាល់ផងដែរមកលើថវិកាប្រមាណ៤លានដុល្លារអាមេរិក ដែលគាំទ្រដោយស៊ីដា-ស៊ុយអែត ដែលបានត្រៀមបម្រុងរួចហើយសម្រាប់គាំទ្រដល់គម្រោងវិនិយោគក្រុង ស្រុក ដែលធនធាននេះនឹងត្រូវប្រើប្រាស់ប្រព័ន្ធមូលនិធិក្រុង ស្រុក។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ គ.ជ.អ.ប នឹងខិតខំសហការសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានាដើម្បីធានានូវការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តចាំបាច់ទាំងនេះឱ្យបានក្នុងត្រីមាសទី១នៃឆ្នាំ២០១២។ បន្ទាប់មក ត្រូវរៀបចំជាបន្ទាន់នូវកម្មវិធីបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុកអំពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ដើម្បីត្រៀមលក្ខណៈសម្រាប់ការចាប់ផ្តើមអនុវត្តមូលនិធិក្រុង ស្រុករបស់ខ្លួនចាប់ពីដើមឆ្នាំ២០១២តទៅ។

**ឃ-) ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ**

គោលបំណងសំខាន់នៃការអភិវឌ្ឍសមត្ថភាពដែលបានកំណត់នៅក្នុងផអ៣ គឺការអភិវឌ្ឍន៍ និងលើកកម្ពស់ការអនុវត្តការងារ និងភាពស័ក្តិសិទ្ធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តអណត្តិរបស់ខ្លួន ដែលរួមទាំងការផ្តល់សេវាសាធារណៈស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

ទោះបីផអ៣បានកំណត់នូវក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលផ្តោតជាសំខាន់លើការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងសមត្ថភាពស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏នៅក្នុងឆ្នាំ២០១១នេះ គឺជាដំណាក់កាលនៃការរៀបចំប្រមូលទិន្នន័យដើមគ្រាសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាព ការសិក្សាជម្រើសនានាសម្រាប់ការរៀបចំប្រព័ន្ធអភិវឌ្ឍន៍សមត្ថភាព និងការចាប់ផ្តើមជ្រើសរើស និងបណ្តុះបណ្តាលនូវគ្រូបង្គោលថ្នាក់ជាតិ។ ការបណ្តុះបណ្តាលមួយចំនួន ដែលបានរៀបចំឡើងនៅក្នុងឆ្នាំ២០១១ គឺជាវគ្គបណ្តុះបណ្តាលរយៈពេលខ្លី សម្រាប់ផ្តល់ការណែនាំតម្រង់ទិសដល់មន្ត្រីថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តោតជាសំខាន់តែទៅលើទស្សនទាន គោលការណ៍ និងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធមួយចំនួនប៉ុណ្ណោះ។ ការអភិវឌ្ឍសមត្ថភាពជំនាញដល់ មន្ត្រីជំនាញ និងការអភិវឌ្ឍសមត្ថភាពផ្នែកស្ថាប័នពុំទាន់ត្រូវបានរៀបចំឡើយ។ លើសពីនេះ ការយឺតយ៉ាវនៃការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធ និងលិខិតបទដ្ឋានគតិយុត្តចាំបាច់មួយចំនួន ដូចជាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ (ជាពិសេសសម្រាប់ថ្នាក់ក្រុង ស្រុក) ក៏ផ្តល់ផលប៉ះពាល់ដល់ការអភិវឌ្ឍសមត្ថភាពផងដែរ។

អាស្រ័យហេតុនេះ ក្នុងឆ្នាំ២០១២ត្រូវផ្តោតការយកចិត្តទុកឱ្យបានខ្លាំងក្លាបន្ថែមទៀត ក្នុងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ទាំងមន្ត្រីរដ្ឋបាល និងក្រុមប្រឹក្សា ដោយផ្តោតជាពិសេសទៅរដ្ឋបាលថ្នាក់ក្រុង ស្រុក រួមជាមួយនឹងការបន្តពង្រឹងសមត្ថភាពរដ្ឋបាលដល់ឃុំ សង្កាត់ផងដែរ។

### ខ-) ការពង្រឹងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ការពង្រឹងគណនេយ្យភាព គឺជាចំណុចស្នូលនៃអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។ ច្បាប់រៀបចំអង្គការ និងកម្មវិធីជាតិបានតម្រូវឱ្យមានការផ្លាស់ប្តូរប្រព័ន្ធអភិបាលកិច្ចនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឈានឆ្ពោះទៅរកប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។ អាស្រ័យហេតុនេះ ការពង្រឹងប្រព័ន្ធគណនេយ្យភាពជាបណ្តើរៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមមាន គណនេយ្យភាពផ្ទៃក្នុងដែលជាទំនាក់ទំនងរវាងអង្គសម្រេចចិត្ត(ក្រុមប្រឹក្សា) ជាមួយអង្គប្រតិបត្តិ (អង្គរដ្ឋបាល) គណនេយ្យភាពពីលើចុះក្រោមរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ និងគណនេយ្យភាពពីក្រោមឡើងលើរវាងប្រភេទផ្សេងគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិ គឺជាការផ្តោតការយកចិត្តដ៏សំខាន់នៃផអ៣។

ក្នុងឆ្នាំ២០១១ ការរៀបចំ និងការអនុវត្តប្រព័ន្ធទាំងនោះ ទើបតែត្រូវបានធ្វើឡើងជាបឋមចំពោះសកម្មភាពជាក់លាក់មួយចំនួនក្នុងក្របខ័ណ្ឌនៃការរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ការចាប់ផ្តើមសិក្សាជាបណ្តើរៗនូវជម្រើសនានាសម្រាប់ការរៀបចំប្រព័ន្ធគណនេយ្យភាពទាំងនេះ ឬស្ថិតនៅក្នុងដំណាក់កាលនៃការអនុវត្តសាកល្បង ដើម្បីដកស្រង់បទពិសោធន៍។ លើសពីនេះ ការខ្វះធនធានសម្រាប់ធ្វើការឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ ដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ដែលបានឯកភាព និងអនុម័តដោយក្រុមប្រឹក្សារបស់ខ្លួន ក៏ជាបញ្ហាប្រឈមគួរឱ្យព្រួយបារម្ភនៃគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ។

អាស្រ័យហេតុនេះ ក្នុងឆ្នាំ២០១២ ត្រូវបន្តការយកចិត្តទុកដាក់បន្ថែមទៀតទៅលើការរៀបចំ និងពង្រឹងការអនុវត្តនូវប្រព័ន្ធគណនេយ្យភាពទាំងនេះ រួមជាមួយនឹងការពង្រឹងសមត្ថភាព និងការយល់ដឹងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីទស្សនទាន និងប្រព័ន្ធគ្រប់គ្រងក្រោមក្របខ័ណ្ឌនៃគោលការណ៍អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ គឺជាលក្ខខណ្ឌចាំបាច់សម្រាប់ប្រសិទ្ធភាពនៃការដឹកនាំ ការសម្រេចចិត្ត ការគ្រប់គ្រង និងការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន។ រៀបចំនិងប្រមូលនូវបទពិសោធន៍ ដែលបានអនុវត្តក្នុងឆ្នាំ២០១១ ដើម្បីចងក្រងធ្វើជាមេរៀនសម្រាប់ពង្រីកការអនុវត្តនៅក្នុងឆ្នាំ២០១២។

### ច-) យន្តការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

យន្តការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាពផ្នែកស្ថាប័ន គឺជាកត្តាចាំបាច់សម្រាប់ភាពជោគជ័យនៃការអនុវត្តកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅក្នុងរបត់ថ្មីនេះ។ ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការអនុវត្តកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដំណាក់កាលកន្លងមក ត្រូវបានរៀបចំឡើងដើម្បីដោះស្រាយបញ្ហាចំពោះមុខរយៈពេលខ្លី និងផ្អែកតាមតម្រូវការដោយឡែកៗរបស់គម្រោង ឬកម្មវិធីអភិវឌ្ឍន៍នានា។ យន្តការគាំទ្របែបនេះ មិនអាចធានាបាននូវភាពជាម្ចាស់ ការទទួលខុសត្រូវ ការអភិវឌ្ឍស្ថាប័ន ការសម្របសម្រួលដើម្បីការ

ស្រុះស្រួល និងឯកភាពគ្នានៅក្នុងរាជរដ្ឋាភិបាលទាំងមូល និងនិរន្តរភាពនៃការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងមានហានិភ័យខ្ពស់នៅពេលដែលគម្រោង ឬកម្មវិធីទាំងនោះត្រូវបានបញ្ចប់។

នៅក្នុងឆ្នាំ២០១១ ទោះបីមានការខិតខំប្រឹងប្រែងរៀបចំ និងពង្រឹងឡើងវិញនូវយន្តការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានលក្ខណៈជាប្រព័ន្ធ និងមាននិរន្តរភាពនៅតាមស្ថាប័ន ការរៀបចំវិធីសាស្រ្តអនុវត្តផអ៣ប្រកបដោយមានការចូលរួម និងទទួលខុសត្រូវដោយក្រសួង ស្ថាប័នពាក់ព័ន្ធសំខាន់ៗមួយចំនួន ការកែសម្រួលរចនាសម្ព័ន្ធនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីធានាបាននូវការពង្រឹងសមត្ថភាពក្នុងការរៀបចំគោលនយោបាយ និងការសម្របសម្រួលកម្មវិធី និងការរៀបចំកែសម្រួលរចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃដើម្បីឆ្លើយតបទៅតាមការវិវត្តនៃកំណែទម្រង់ ក៏កិច្ចការទាំងនេះមួយចំនួនមិនទាន់ត្រូវបានរៀបចំបញ្ចប់ទាំងស្រុង និងមួយចំនួនទៀតកំពុងស្ថិតនៅក្នុងដំណាក់កាលសិក្សានៅឡើយ។

ដើម្បីដោះស្រាយបាននូវបញ្ហាដ៏មានសារៈសំខាន់នេះ តម្រូវឱ្យបន្តការយកចិត្តទុកដាក់ដើម្បីធានាឱ្យបានថា រចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុកត្រូវមានមន្ត្រីគ្រប់គ្រាន់ និងប្រកបដោយសមត្ថភាពសមស្របសម្រាប់ការគាំទ្រដល់ឃុំ សង្កាត់។ រដ្ឋបាលរាជធានី ខេត្តត្រូវទទួលបាននូវមុខងារ ធនធាន និងសមត្ថភាពសមស្របសម្រាប់ផ្តល់ការគាំទ្រដល់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ដោយឡែក រចនាសម្ព័ន្ធថ្មីនៃលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបានរៀបចំនូវមន្ត្រីដែលមានសមត្ថភាពសមស្រប ជាពិសេសសម្រាប់ការអភិវឌ្ឍន៍គោលនយោបាយ និងមានយន្តការអនុវត្តការងារសមស្របសម្រាប់សម្របសម្រួលការអនុវត្តកម្មវិធី។ រចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃក៏ត្រូវខិតខំបញ្ចប់នូវការកែសម្រួល ដើម្បីឆ្លើយតបបានទៅនឹងស្ថានភាពជាក់ស្តែងនៃកិច្ចដំណើរការនៃកំណែទម្រង់។

**ឆ-) ការបញ្ជ្រាបយេនឌ័រ**

ការជំរុញ និងពង្រឹងលើការអនុវត្តគោលនយោបាយសមភាពយេនឌ័ររបស់រាជរដ្ឋាភិបាលក្នុងកិច្ចដំណើរកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាគោលបំណងដ៏សំខាន់មួយនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ទោះបីជាផអ៣ នៃកម្មវិធីជាតិបានកំណត់ជាស្រេចនូវយុទ្ធសាស្រ្តសម្រាប់ការបញ្ជ្រាបយេនឌ័រ ក៏នៅក្នុងឆ្នាំ២០១១នេះ យុទ្ធសាស្រ្តនេះពុំទាន់ត្រូវបានចាប់ផ្តើមអនុវត្តបានពេញលេញ នៅតាមអនុកម្មវិធីនីមួយៗឡើយ។ ដើម្បីប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្រ្តនេះ និងពង្រឹងភាពម្ចាស់ការលើការលើកកម្ពស់សមភាពយេនឌ័ររបស់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា គឺតម្រូវឱ្យមានការពិនិត្យឡើងវិញនូវយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រនៃផអ៣ ដើម្បីរំលេចទស្សនៈទាន និងការយកចិត្តទុកដាក់លើការលើកកម្ពស់សមភាពយេនឌ័រ ក្នុងផែនការសកម្មភាព និងថវិកា និងរាល់ដំណើរការងាររបស់អនុកម្មវិធីនីមួយៗ ដែលកិច្ចការនេះទើបតែបានរៀបចំបញ្ចប់នៅក្នុងឆ្នាំ២០១១។ អាស្រ័យហេតុនេះ ដើម្បីធានាបាននូវការអនុវត្តយុទ្ធសាស្រ្តយេនឌ័រឱ្យបានពេញលេញនៅក្នុងឆ្នាំ២០១២ ត្រូវផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត ទៅលើការ

អភិវឌ្ឍសមត្ថភាព និងការប្តេជ្ញាចិត្តរបស់អនុកម្មវិធីទាំងប្រាំមួយនៃផអព និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថាបញ្ហាយេនឌ័រត្រូវបានគិតគូរយ៉ាងហ្មត់ចត់ និងបានដាក់បញ្ចូលទៅក្នុងរាល់គោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធ ព្រមទាំងត្រូវបានយកចិត្តទុកដាក់ជាប្រចាំក្នុងការអនុវត្ត។ ក្រសួងកិច្ចការនារីត្រូវបន្តការគាំទ្របច្ចេកទេសដល់អនុកម្មវិធីនីមួយៗ និងដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមតម្រូវការចាំបាច់។ លើសពីនេះយន្តការបញ្ជ្រាបយេនឌ័រ ក្នុងអនុកម្មវិធីនីមួយៗនឹងត្រូវរៀបចំ និងបង្កើតឡើង ដើម្បីធានានិរន្តរភាពនៃកិច្ចការនេះ។

**ជ-) ការផ្សព្វផ្សាយព័ត៌មាន**

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ទើបនឹងចាប់ផ្តើមនៅក្នុងទសវត្សរ៍ចុងក្រោយនេះ ហើយកិច្ចដំណើរការនៃកំណែទម្រង់នេះក៏មានការវិវត្តជាប្រចាំ ដែលការលើកកម្ពស់ការយល់ដឹងដល់ស្ថាប័នអនុវត្តន៍នានានៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដូចជាក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងសាធារណជនទូទៅអំពីកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនេះ គឺពិតជាការចូលរួមចំណែកដែលមិនអាចខ្វះបាន និងមានសារៈសំខាន់ជាទីបំផុត។ មកទល់បច្ចុប្បន្ននេះ ទោះបីតាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់យន្តការនានានៃរចនាសម្ព័ន្ធ គ.ជ.អ.ប ក្នុងការពង្រីកនូវការយល់ដឹងនេះ នៅក្នុងចំណោមក្រសួង ស្ថាប័ន មន្ត្រីរាជការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដល់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ក៏ការផ្សព្វផ្សាយនេះនៅពុំទាន់មានភាពស៊ីជម្រៅ និងទូលំទូលាយ ជាពិសេសនៅក្នុងចំណោមប្រជាពលរដ្ឋជាទូទៅនៅឡើយ។

អាស្រ័យហេតុនេះ ការបន្ត និងជំរុញការផ្សព្វផ្សាយអំពីគោលនយោបាយនៃកំណែទម្រង់ដ៏មានសារៈសំខាន់នេះ សម្រាប់បង្កើនការយល់ដឹងដល់ក្រសួង ស្ថាប័ន មន្ត្រីរាជការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដល់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ មជ្ឈដ្ឋានសិស្ស និស្សិត និងប្រជាពលរដ្ឋនៅមូលដ្ឋាននានា តាមរយៈយន្តការដែលមានស្រាប់របស់ គ.ជ.អ.ប និងតាមបណ្តាញផ្សព្វផ្សាយព័ត៌មាននានាដែលមានជាអាទិ៍ដូចជា គេហទំព័រ កម្មវិធីវិទ្យុ និងទូរទស្សន៍ សារព័ត៌មាន ព្រឹត្តិបត្រព័ត៌មាន ខិត្តប័ណ្ណ ប្រតិទិនប្រចាំឆ្នាំ ទិន្នានុលេខន៍ គឺជាវិធានការចាំបាច់ និងមានសារសំខាន់សម្រាប់ការអនុវត្តក្នុងឆ្នាំ២០១២តទៅ។

**ឈ-) ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**

ការរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ គឺជាកត្តាសំខាន់សម្រាប់តាមដាន និងកំណត់បាននូវបញ្ហាប្រឈមនានាដែលជួបប្រទះក្នុងពេលអនុវត្ត ដើម្បីឈានទៅរកដំណោះស្រាយបានទាន់ពេលវេលា។ ប្រព័ន្ធនេះក៏មានសារសំខាន់សម្រាប់ការវាស់វែង និងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីប្រៀបធៀបទៅនឹងចំណុចដៅនានាដែលបានគ្រោងទុក។ ទាំងកម្មវិធីជាតិ និងផអពបានកំណត់នូវសូចនាករ និងចំណុចដៅគន្លឹះ៧នៃកិច្ចដំណើរការកំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សម្រាប់ធ្វើការវាស់វែងនូវវឌ្ឍភាពនៃការអនុវត្ត។ ក្នុងឆ្នាំ២០១១ ប្រព័ន្ធត្រួតពិនិត្យតាមដានត្រូវបានរៀបចំ និងផ្តល់ការបណ្តុះបណ្តាល

ដល់ក្រសួង ស្ថាប័នអនុវត្តអនុកម្មវិធីទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទោះបីប្រព័ន្ធនេះ ត្រូវបានរៀបចំបណ្តុះបណ្តាល និងដាក់ឱ្យអនុវត្តជាបណ្តើរៗក្តី ក៏ប្រព័ន្ធនេះផ្តោតជាសំខាន់ទៅលើតែការរៀបចំរបាយការណ៍។ ក្នុងការអនុវត្តជាក់ស្តែង ក៏បានជួបប្រទះនូវបញ្ហាប្រឈមជាច្រើន ដែលតម្រូវឱ្យមានការកែលំអ។ បញ្ហាប្រឈមទាំងនោះរួមមានដូចជា ការយឺតយ៉ាវក្នុងការរៀបចំ និងផ្ញើរបាយការណ៍ ដោយសារកង្វះខាតប្រព័ន្ធតាមដាននិងត្រួតពិនិត្យតាមរយៈប្រព័ន្ធកុំព្យូទ័រ កង្វះប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់អនុកម្មវិធីនីមួយៗ និងកង្វះខាតនៃប្រព័ន្ធដើម្បីធានាបាននូវព័ត៌មានប្រកបដោយសុក្រិតភាព និងដែលអាចទទួលយកបាន។

ដើម្បីដោះស្រាយបាននូវបញ្ហាទាំងនេះ គឺត្រូវបន្តការយកចិត្តទុកដាក់ក្នុងការសម្របសម្រួល និងបន្តពង្រឹងសមត្ថភាពក្រសួង ស្ថាប័នអនុវត្តអនុកម្មវិធី និងអង្គភាពពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបានថាប្រព័ន្ធរបាយការណ៍ត្រូវបានអនុវត្តតាមយ៉ាងទាន់ពេលវេលា។ អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាននៃលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវអភិវឌ្ឍនូវប្រព័ន្ធកុំព្យូទ័រដែលអាចធ្វើការតាមដាន វាយតម្លៃ ប្រកបដោយភាពរលូន ទៀតទាត់ពេលវេលា និងត្រូវសិក្សា និងកែសម្រួលប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់អនុកម្មវិធីនីមួយៗ។

**៣-) ប្រព័ន្ធចំណាយប្រតិបត្តិការអាទិភាព (POC)**

ប្រព័ន្ធចំណាយប្រតិបត្តិការអាទិភាព ត្រូវបានឯកភាពដាក់ឱ្យប្រើប្រាស់ក្នុងការអនុវត្តផអ៣ ដើម្បីជំរុញលើកទឹកចិត្តដល់មន្ត្រីរដ្ឋាភិបាលឱ្យចូលរួមកាន់តែសកម្មក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃផអ៣។ ការយឺតយ៉ាងនៃការរៀបចំប្រព័ន្ធនេះ ដែលអូសបន្លាយរហូតដល់ចុងឆមាសទី១នៃឆ្នាំ២០១១ បានធ្វើឱ្យប៉ះពាល់ដល់ការចូលរួមនិងភាពម្ចាស់ការ និងការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីក្នុងការអនុវត្តការងារជាច្រើន។ យោងតាមការតាំងចិត្តរបស់ដៃគូអភិវឌ្ឍន៍នានា ប្រព័ន្ធលើកទឹកចិត្តនេះ នឹងត្រូវបញ្ចប់នៅចុងឆមាសទី១នៃឆ្នាំ២០១២ខាងមុខនេះ ដែលយើងអាចប្រមើលឃើញអំពីផលប៉ះពាល់ដែលយើងធ្លាប់ជួបប្រទះកន្លងមក ក្នុងពេលដែលគ្មានប្រព័ន្ធនេះ។

# IV.ផែនការឆ្នាំ២០១២

ផ្អែកលើវឌ្ឍនភាពដែលសម្រេចបាន និងបញ្ហាប្រឈមជាគន្លឹះនានាដែលជួបប្រទះក្នុងការអនុវត្តកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅក្នុងឆ្នាំ២០១១នេះ បានផ្តល់មេរៀន និងបទពិសោធន៍ល្អៗជាច្រើន សម្រាប់ការកែលំអលើការរៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១២។ ដើម្បីបន្តអនុវត្តកិច្ចដំណើរការនៃកំណែទម្រង់នេះ ឱ្យមានភាពរលូនតាមផែនការដែលគ្រោងក្នុងផអ៣ និងដើម្បីធានាដោះស្រាយបាននូវបញ្ហាសំខាន់ៗមួយចំនួនដូចបានរៀបរាប់នៅខាងលើ ក្នុងឆ្នាំ២០១២ ចាំបាច់ ត្រូវផ្តោតការយកចិត្តទៅលើសកម្មភាពជាអាទិភាពនានាដូចខាងក្រោម៖

- **ការរៀបចំមូលនិធិក្រុង ស្រុក និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក៖** ត្រូវបន្តរៀបចំបញ្ចប់ និងដាក់ឱ្យអនុវត្តនូវអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក និងអនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានានៅក្នុងអំឡុងត្រីមាសទី១នៃឆ្នាំ២០១២។ ជាមួយគ្នានេះ ត្រូវរៀបចំ និងផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថា រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពក្នុងការអនុវត្តប្រព័ន្ធនេះជាបណ្តើរៗនៅក្នុងឆ្នាំ២០១២។
- **ការរៀបចំ បង្កើតយន្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌទៅរដ្ឋបាលថ្នាក់ក្រោមជាតិ៖** ត្រូវបន្តការសិក្សាដើម្បីរៀបចំបង្កើតយន្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះរួមមានការរៀបចំបង្កើតយន្តការផ្តល់ហិរញ្ញប្បទានវិនិយោគទៅរដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) ដើម្បីឈានទៅអនុវត្តយន្តការនេះជាបណ្តើរៗនៅឆ្នាំ២០១៣។
- **គោលនយោបាយស្តីពីចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** ត្រូវបន្តសិក្សាបញ្ចប់ និងដាក់ចេញនូវគោលនយោបាយស្តីពីចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងឆ្នាំ២០១២ ដើម្បីអនុញ្ញាតឱ្យរដ្ឋបាល ថ្នាក់ក្រោមជាតិ អាចមានលទ្ធភាពក្នុងការទទួលបានចំណូលពីប្រភពចំណូលផ្ទាល់របស់ខ្លួនដែលបានកំណត់ឱ្យពីឆ្នាំ២០១៣តទៅ។
- **គោលការណ៍ណែនាំស្តីពីការអនុវត្តគម្រោងអភិវឌ្ឍន៍ក្រុង ស្រុក (DIM)៖** ក្នុងខណៈដែលរដ្ឋបាលក្រុង ស្រុកមានមូលនិធិ និងធនធានរបស់ខ្លួននៅក្នុងឆ្នាំ២០១២នេះ ចាំបាច់ត្រូវមាននីតិវិធីសមស្របសម្រាប់ក្រុង ស្រុកក្នុងការរៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍន៍នានាដោយប្រើប្រាស់ធនធានដែលខ្លួនមាន។ ដូចនេះ គោលការណ៍ណែនាំស្តីពីនីតិវិធីនៃការអនុវត្តគម្រោងអភិវឌ្ឍន៍ក្រុង ស្រុក ត្រូវតែបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ចាប់ពីត្រីមាសទី២នៃឆ្នាំ២០១២តទៅ។

- **ការពិនិត្យមើលឡើងវិញនូវប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** ត្រូវរៀបចំឱ្យមានការសិក្សា និងវាយតម្លៃលើប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលកំពុងត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីឈានទៅកែលំអឱ្យមានលក្ខណៈងាយស្រួល និងសមស្របទៅតាមចរិកលក្ខណៈ និងស្ថានភាពផ្សេងៗគ្នានៃប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងមានសង្គតិភាពជាមួយដំណើរការរៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះ។
- **គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ៖** ត្រូវបន្តរៀបចំបញ្ចប់នូវក្របខ័ណ្ឌគតិយុត្តសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ នៅមុនពេលមានការរៀបចំនូវលក្ខន្តិកៈដោយឡែកស្ដីពីការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវរៀបចំ និងដាក់ចេញនូវគោលនយោបាយស្ដីពីការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឈានទៅរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។
- **ការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ៖** ត្រូវរៀបចំបញ្ចប់ និងដាក់ចេញនូវ អនុក្រឹត្យស្ដីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងត្រីមាសទី១នៃឆ្នាំ២០១២។ ការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ននៃវិស័យអាទិភាពមួយចំនួននៅក្នុងត្រីមាសទី២ និងការរៀបចំពិនិត្យឡើងវិញនូវមុខងារ និងធនធាននៅក្នុងត្រីមាសទី៣ ដើម្បីឈានទៅអនុវត្តសាកល្បងនូវការផ្ទេរមុខងារ និងធនធាននៃវិស័យអាទិភាពមួយចំនួនឱ្យទៅ រដ្ឋបាលថ្នាក់ក្រោមជាតិនៅចុងឆ្នាំ២០១២។
- **ការពិនិត្យ និងកែសម្រួលក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាព** ៖ត្រូវបន្តពិនិត្យ និងកែសម្រួលក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានចប់នៅដើមឆ្នាំ២០១២ និងឈានទៅដល់ការចាប់ផ្ដើមអនុវត្តពេញលេញនូវក្របខ័ណ្ឌនេះ ពីក្នុងត្រីមាសទី១នៃឆ្នាំ២០១២តទៅ។ ជាមួយគ្នានេះដែរ ក៏ត្រូវបន្តការសិក្សាលើជម្រើសនៃការបង្កើតវិទ្យាស្ថានជាតិ សម្រាប់ការបណ្ដុះបណ្ដាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចនៅក្នុងឆ្នាំ២០១២។
- **ប្រព័ន្ធពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ៖** បន្តការរៀបចំបង្កើតប្រព័ន្ធពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ជ្រើសរើសអ្នកហ្វឹកហ្វឺន និងរៀបចំបញ្ចប់ឯកសារបច្ចេកទេស និងឯកសារបណ្ដុះបណ្ដាលស្ដីពីនីតិវិធីកិច្ចប្រជុំ និងនីតិវិធីនៃការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាសាធារណៈរបស់ក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីឈានទៅរៀបចំ និងផ្ដល់ការបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិជាបណ្ដើរៗពីត្រីមាសទី២នៃឆ្នាំ២០១២តទៅ។

- **វិធានគ្រប់គ្រងក្រុង ស្រុក៖** បន្តសិក្សា និងរៀបចំបញ្ចប់សេចក្តីព្រាងគំរូនៃវិធានគ្រប់គ្រងក្រុង ស្រុក នៅក្នុងត្រីមាសទី២នៃឆ្នាំ២០១២ ដើម្បីដាក់ឱ្យពិភាក្សា និងពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ និងឈានទៅអនុវត្តសាកល្បងនៅក្នុងក្រុង ស្រុកមួយចំនួននៅចុងឆ្នាំ២០១២។
- **ការរៀបចំបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ៖** ជំរុញការរៀបចំបង្កើតសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ តាមជម្រើសនានាដែលបានសិក្សានៅក្នុងឆ្នាំ២០១១ឱ្យបានរួចរាល់នៅក្នុងឆ្នាំ២០១២។
- **ជំរុញការបញ្ជ្រាបយេនឌ័រនៅក្នុងកិច្ចដំណើរការកំណែទម្រង់៖** ការបញ្ជ្រាបយេនឌ័រ ក្នុងគោលបំណងលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចក្លាហានរបស់ស្ត្រីក្នុងកិច្ចដំណើរការកំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាគោលបំណងដ៏សំខាន់មួយនៃកម្មវិធីជាតិ។ ដើម្បីសម្រេចបានតាមគោលបំណងនេះ ក្នុងឆ្នាំ២០១២ គ.ជ.អ.ប នឹងបន្តកិច្ចសហការជាមួយក្រសួងកិច្ចការនារី ក្នុងការរៀបចំ និងផ្តល់ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពីការវិភាគយេនឌ័រ នៅតាមបរិបទនៃអនុកម្មវិធីនីមួយៗ ។ លើសពីនេះ ត្រូវរៀបចំសិក្សា និងពិគ្រោះយោបល់រវាងស្ថាប័នអនុវត្តអនុកម្មវិធីនីមួយៗជាមួយក្រុមការងារយេនឌ័រនៃក្រសួងសាមុី ដើម្បីពិភាក្សាពីលទ្ធភាពនៃការធ្វើការរួមគ្នារវាងក្រុមទាំងពីរនេះ សំដៅបង្កើតយន្តការរយៈពេលវែងសម្រាប់ការងារបញ្ជ្រាបយេនឌ័រ។
- **ការពង្រឹងប្រព័ន្ធព័ត៌មានវិទ្យា៖** ត្រូវបន្តពង្រឹង និងពង្រីកបណ្តាញព័ត៌មានវិទ្យាពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រុង ស្រុក ខណ្ឌ ឱ្យបានពេញលេញនៅក្នុងឆ្នាំ២០១២ ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទងការងារ និងផ្សព្វផ្សាយព័ត៌មាន។
- **ការពង្រឹងលក្ខខណ្ឌការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** ត្រូវបន្តបញ្ចប់ការសិក្សា និងលើកគម្រោងក្នុងការពង្រឹងលក្ខខណ្ឌការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលថ្នាក់ក្រុង ស្រុក ដើម្បីឱ្យរដ្ឋបាលទាំងនោះមានលទ្ធភាព និងលក្ខខណ្ឌល្អប្រសើរជាបន្តបន្ទាប់ក្នុងការបំពេញការងាររបស់ខ្លួន។

## V. សេចក្តីសន្និដ្ឋាន

ក្នុងក្របខ័ណ្ឌនៃការអនុវត្តកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជាឆ្នាំ២០១១ គឺជាឆ្នាំអន្តរកាលនៃការតភ្ជាប់ពីដំណាក់កាលទី១ ឈានចូលមកដំណាក់កាលទី២ ដែលមានលក្ខណៈកាន់តែស៊ីជម្រៅ និងរសើប និងត្រូវអនុវត្តក្នុងក្របខ័ណ្ឌនៃរបត់ និងវិធីសាស្ត្រថ្មីមួយ ដែលបានកំណត់ដោយផអ៣ និងកម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ផ្អែកលើការយកចិត្តទុកដាក់ និងការខិតខំប្រឹងប្រែងរបស់ គ.ជ.អ.ប និងការចូលរួមចំណែកយ៉ាងសកម្មពីសំណាក់ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធទាំងអស់ បានជំរុញឱ្យយើងឆ្លងផុតនូវដំណាក់កាលអន្តរកាលដ៏លំបាកស្មុគស្មាញក្នុងឆ្នាំ២០១១នេះ ប្រកបដោយជោគជ័យ និងស្របតាមទិសដៅ និងគោលការណ៍នៃការចូលរួមលើកកម្ពស់ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និងប្រសិទ្ធភាពក្នុងការអនុវត្តដែលបានកំណត់នៅក្នុងកម្មវិធីជាតិ។

សមិទ្ធផលសំខាន់ និងគួរជាទីមោទនៈជាច្រើនត្រូវបានសម្រេចនៅក្នុងឆ្នាំ២០១១នេះ ដែលក្នុងនោះរួមមានសមិទ្ធផលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍គោលនយោបាយ ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនានារបស់ស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំ និងអនុវត្តកម្មវិធី ផែនការសកម្មភាព និងថវិកាសម្រាប់គាំទ្រដល់ប្រតិបត្តិការ និងការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ការកៀរគរការបន្តគាំទ្រ និងការចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ព្រមទាំងការសម្របសម្រួល និងការធ្វើឱ្យមានសង្គតិភាពនៃកិច្ចដំណើរការកំណែទម្រង់លើវិស័យសំខាន់ៗផ្សេងទៀត កម្មវិធី និងគម្រោងអភិវឌ្ឍន៍នានាជាមួយនឹងកិច្ចដំណើរការនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ទន្ទឹមនឹងសម្រេចបាននូវសមិទ្ធផលគួរជាទីមោទនៈ ក៏មានបញ្ហាប្រឈមជាច្រើន ដែលត្រូវផ្តោតការយកចិត្តទុកក្នុងការដោះស្រាយទាំងក្នុងក្របខ័ណ្ឌនៃការសម្រេចចិត្តខាងនយោបាយជាលក្ខណៈបន្ទាន់ចំពោះមុខ និងសម្រាប់រយៈពេលវែង និងទាំងក្នុងកម្រិតផ្នែកបច្ចេកទេសសម្រាប់ការកែលំអប្រសិទ្ធភាពនៃប្រតិបត្តិការក្នុងការអនុវត្តកម្មវិធី។ បញ្ហាប្រឈមដែលតម្រូវឱ្យមានការសម្របសម្រួលផ្នែកនយោបាយ គឺពាក់ព័ន្ធជាសំខាន់លើការរៀបចំប្រព័ន្ធផ្ទេរហិរញ្ញប្បទាន និងគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក និងការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងបុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ បញ្ហាប្រឈមដែលតម្រូវឱ្យមានដំណោះស្រាយផ្នែកបច្ចេកទេស រួមមានពាក់ព័ន្ធនឹងការពង្រឹងប្រព័ន្ធអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ការពង្រឹងយន្តការគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ ការជំរុញការផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយដល់សាធារណជន ការកែលំអប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកម្មវិធី ក៏ដូចជាលើការអនុវត្តកិច្ចដំណើរការនៃកំណែទម្រង់ទាំងមូល។

ជារួម ការចាប់ផ្តើមអនុវត្តនូវកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងរបត់ថ្មីក្រោមក្របខ័ណ្ឌកម្មវិធីជាតិនៅក្នុងឆ្នាំ២០១១នេះ អាចវាយតម្លៃបានថាជាការចាប់ផ្តើមដ៏ត្រឹមត្រូវតាមគោលនយោបាយ យុទ្ធសាស្ត្រ និងគោលការណ៍នានាដែលបានកំណត់នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់រៀបចំអង្គការ និងកម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលជាជោគជ័យមួយរបស់រាជរដ្ឋាភិបាលក្នុងវិស័យកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងព្រមទាំងបានផ្តល់នូវបទពិសោធន៍ និងមេរៀនសំខាន់ៗជាច្រើន សម្រាប់ធ្វើជាមូលដ្ឋានក្នុងការកែលំអការអនុវត្តកិច្ចដំណើរការនៃកំណែទម្រង់នេះនៅក្នុងឆ្នាំ២០១២ និងឆ្នាំបន្តបន្ទាប់ទៅមុខទៀត។

របាយការណ៍នេះ បានអនុម័តក្នុងកិច្ចប្រជុំ គ.ជ.អ.ប លើកទី៦នាថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២។

**រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១២**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**ស ខេង**